កំណត់ត្រាសង្ខេប ៖ ទិដ្ឋភាពរួមនៃច្បាប់កម្ពុជា ពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិ និងការសង្ខេបករណីសិក្សាថ្មីៗដើម្បីបង្ហាញពីរបៀបអនុវត្តច្បាប់ និងការអនុវត្តន៍ទាំងបំពានក្នុងការប្រឆាំងសំឡេងដំណាស់

សេចក្តីផ្តើម

កំណត់ត្រាសង្ខេបនេះ បង្ហាញពីសិទ្ធិសេរីភាពបញ្ចេញមតិដែលត្រូវបានការពារក្នុងច្បាប់កម្ពុជា បង្ហាញពីទិដ្ឋភាពរួមនៃបញ្ញត្តច្បាប់ដែលកំពុងត្រូវបានអនុវត្តទាំងអស់ ពាក់ព័ន្ធនឹងបទបរិហារកេរ្តិ៍ ឬបញ្ញត្តច្បាប់ដែលមានឥទ្ធិពលមកលើសិទ្ធិសេរីភាពបញ្ចេញមតិក្នុងព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) និងពិភាក្សាអំពីករណីសិក្សាថ្មីៗមួយចំនួនដែលបទប្បញ្ញត្តទាំងនេះត្រូវបានប្រើប្រាស់ដើម្បីជាឧបករណ៍បិទមាត់អ្នករិះគន់រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) និងគោលនយោបាយរបស់ខ្លួន។ កំណត់ត្រាសង្ខេបនេះ នឹងត្រូវបានប្រើជាគោល-ការណ៍ណែនាំផ្នែកច្បាប់ សម្រាប់ជាប្រយោជន៍ដល់អ្នកការពារសិទ្ធិមនុស្សទាំងអស់ រួមមានទាំង អ្នកសារព័ត៌មាន សកម្មជនសិទ្ធិមនុស្ស បុគ្គលិកនៃអង្គការមិនមែនរដ្ឋាភិបាល មេធាវី និងអ្នកនយោបាយ ក៏ដូចជាត្រូវបានប្រើប្រាស់ សម្រាប់លើកកម្ពស់ការយល់ដឹងអំពីរបៀបដែលសេរីភាពបញ្ចេញមតិត្រូវបានការពារតាមទ្រឹស្តី ប៉ុន្តែត្រូវបានរំលោភបំពានក្នុងការអនុវត្តន៍ជាក់ស្តែងនៅប្រទេសកម្ពុជាសម័យបច្ចុប្បន្ន។

សិទ្ធិសេរីភាពបញ្ចេញមតិ

គណៈកម្មាធិការសិទ្ធិមនុស្ស អ្នកតាមដានមើលកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.ស.អ.ព.ន) បញ្ជាក់ថា "*សេរីភាពបញ្ចេញមតិគឺលក្ខខណ្ឌដ៏ចាំបាច់ដើម្បីទទួលស្គាល់នូវគោលការណ៍តម្លាភាព និងគណនេយ្យភាព ដូច្នេះគឺស្មើនឹងថាមានសារៈសំខាន់ចំពោះការលើកដម្កើង និងការពារសិទ្ធិមនុស្សផងដែរ*" ។[1]

សិទ្ធិសេរីភាពបញ្ចេញមតិត្រូវបានធានាក្នុងច្បាប់កម្ពុជា។ មាត្រា៤១ ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) ចែងថាប្រជាពលរដ្ឋខ្មែរទាំងអស់មានសេរីភាពបញ្ចេញមតិ។ មាត្រា៣១ ចែងថាកម្ពុជាទទួលស្គាល់ និងគោរពសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (ស.ស.ស.ម) និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស រាប់បញ្ចូលទាំង ក.អ.ស.ព.ន ផងដែរ។ បន្ថែមពីលើនោះ ក.អ.ស.ព.ន គឺត្រូវបានបញ្ចូលទៅក្នុងច្បាប់ប្រទេសកម្ពុជាដោយសារតែកម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញានេះក្នុងឆ្នាំ១៩៩២ ដែលការដាក់បញ្ចូលនេះត្រូវបានធានាដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដែលបញ្ជាក់ថា "*កតិកាសញ្ញាអន្តរជាតិដែលកម្ពុជាទទួលស្គាល់*" បង្កើតជាផ្នែកមួយនៃច្បាប់កម្ពុជា។[2] មាត្រា១៩ នៅក្នុង ស.ស.ស.ម និង ក.អ.ស.ព.ន ចែងពីសិទ្ធិសេរីភាពបញ្ចេញមតិរបស់បុគ្គលគ្រប់រូប។ បន្ថែមពីលើនោះ មាត្រា៣៥ នៃរដ្ឋធម្មនុញ្ញបានចែងថាប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយរបស់ប្រទេសជាតិ។

ការដកបទបរិហារកេរ្តិ៍ចេញពីបទឧក្រិដ្ឋ?

ក្នុងដំណើរការឆ្ពោះទៅកិច្ចប្រជុំ "ក្រុមពិគ្រោះយោបល់" ដើម្បីពិភាក្សាពីការផ្តល់ជំនួយ ជាមួយម្ចាស់ជំនួយអន្តរជាតិដែលបានប្រារព្ធឡើងក្នុងខែមិនា ឆ្នាំ២០០៦[3] លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសន្យាជាមួយសហគមន៍អន្តរជាតិថានឹងដកបទបរិហារកេរ្តិ៍ចេញពី

---

[1] គណៈកម្មាធិការសិទ្ធិមនុស្ស ការផ្តល់យោបល់ទូទៅលេខ ៣៤ កិច្ចប្រជុំលើកទី ១០២ ក្រុងសឺណែវ ថ្ងៃទី១១-២៩ ខែកក្កដា ឆ្នាំ២០១១ (CCPR/C/GC/៣៤) កំណត់សម្គាល់ទូទៅទី៣។

[2] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។

[3] លីកាដូ "របាយការណ៍សង្ខេប ៖ ការវាយប្រហារ និងការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា" ខែធ្នូ ឆ្នាំ២០០៦ ទំព័រ៤ អាចអានបាន ៖ http://www.licadho-cambodia.org/reports/files/98LICADHOPaperHumanRightsDefender2006.pdf ។

បទល្មើសព្រហ្មទណ្ឌ។[4] ជាលទ្ធផល នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៦ រដ្ឋសភាបានធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌកម្ពុជាដែលមានស្រាប់ ដោយបានលុបចោលការដាក់ពន្ធនាគារចេញពីការផ្តន្ទាទោសចំពោះបទបរិហារកេរ្តិ៍។ ទោះបីជានេះជាជំហានឆ្ពោះទៅរកទិសដៅដ៏ត្រឹមត្រូវមួយដោយគ្មានការសង្ស័យក៏ដោយ ប៉ុន្តែការលុបចោលការដាក់ពន្ធនាគារចេញពីការផ្តន្ទាទោស មិនស្មើនឹងការដកបទបរិហារកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌនោះទេ។[5] រយៈពេលជាងប្រាំមួយឆ្នាំបានកន្លងផុត បទបរិហារកេរ្តិ៍នៅតែជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសដោយការពិន័យជាប្រាក់យ៉ាងធ្ងន់ធ្ងរ។ ការពិត បទល្មើសនេះត្រូវបានបញ្ចូលទៅក្នុងក្រមព្រហ្មទណ្ឌថ្មី ដែលចូលជាធរមានក្នុងខែធ្នូ ឆ្នាំ ២០១០ មានឈ្មោះថា ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ (ក្រមព្រហ្មទណ្ឌ) ហើយមើលទៅរដ្ឋាភិបាលកំពុងតែបានព្យាយាមគេចវេះមិនព្រមធ្វើតាមការសន្យារបស់លោកនាយករដ្ឋមន្ត្រីកាលពីលើកមុន។ ម្យ៉ាងវិញទៀត ការមិនបង់ប្រាក់ពិន័យ ក៏នៅតែចាត់ទុកជាបទល្មើសដែលអាចផ្តន្ទាទោសដាក់ពន្ធនាគារ តាមមាត្រា ៥២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ក្រមនីតិវិធីព្រហ្មទណ្ឌ)។ លក្ខខណ្ឌនៃការដាក់ពន្ធនាគារចំពោះការមិនព្រមបង់ប្រាក់ពិន័យ បានកំណត់ក្នុងមាត្រា ៥៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមានរយៈពេលចាប់ពី ១០ ថ្ងៃ ដល់ ២ឆ្នាំ អាស្រ័យទៅលើចំនួនទឹកប្រាក់ពិន័យ។ ការមិនបង់ប្រាក់ពិន័យចាប់ពី ប្រាំលាននិងមួយរៀល[6] ទៅដប់លានរៀល ដែលចំនួនដប់លានរៀលជាចំនួនទឹកប្រាក់អតិបរមានៃការពិន័យចំពោះបទបរិហារកេរ្តិ៍ នឹងត្រូវជាប់ពន្ធនាគាររយៈពេលប្រាំមួយខែ។ ដូច្នេះ ការលុបចោលការដាក់ពន្ធនាគារចេញពីការផ្តន្ទាទោសលើបទបរិហារកេរ្តិ៍ គឺមានន័យថាជនជាប់ចោទនៅតែប្រឈមនឹងការជាប់ពន្ធនាគាររយៈពេល ៦ខែ ចំពោះបទល្មើសដដែលនេះ។

ច្បាប់នានាស្តីពីបទបរិហារកេរ្តិ៍

ច្បាប់ដែលពាក់ព័ន្ធនឹងបទល្មើសនៃសេរីភាពបញ្ចេញមតិបំផុតនៅកម្ពុជា មានដូចជា (១) ក្រមព្រហ្មទណ្ឌ (២) បទប្បញ្ញត្តស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ឆ្នាំ១៩៩២ (ក្រមព្រហ្មទណ្ឌអន្តរកាល) និង (៣) ច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥។ បទប្បញ្ញត្តពាក់ព័ន្ធនឹងច្បាប់ទាំងនេះនឹងបង្ហាញក្នុងផ្នែកទាំងបីខាងក្រោម។

១. ក្រមព្រហ្មទណ្ឌ

តាមការរៀបរាប់ខាងលើ ក្រមព្រហ្មទណ្ឌចូលជាធរមានក្នុងខែធ្នូ ឆ្នាំ២០១០។ ក្រុមអង្គការសិទ្ធិមនុស្ស ដែលរួមមាន ម.ស.ម.ក[7] និងអង្គការមាត្រា១៩[8] បានរិះគន់ដល់ក្រមព្រហ្មទណ្ឌ ថាជាអាវុធមួយរបស់រដ្ឋាភិបាល និងគណបក្សកាន់អំណាចគឺគណបក្សប្រជាជនកម្ពុជា សម្រាប់ប្រើក្នុងយុទ្ធនាការដើម្បីបំបិទមាត់ជាបន្តបន្ទាប់ដល់ក្រុមបុគ្គលដែលហ៊ាននិយាយប្រឆាំងនឹងគោលនយោបាយ សកម្មភាព ឬការខកខានរបស់រដ្ឋាភិបាល។ ក្រមព្រហ្មទណ្ឌបានរក្សាបទបរិហារកេរ្តិ៍ជាបទល្មើសព្រហ្មទណ្ឌ ទោះបីជា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសន្យាកាលពីខែកុម្ភៈ ឆ្នាំ២០០៦ ថានឹងដកបទបរិហារកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌក៏ដោយ។

ការពិត ក្រមព្រហ្មទណ្ឌបានពង្រីកវិសាលភាពនៃបទបរិហារកេរ្តិ៍មិនត្រឹមតែអនុវត្តចំពោះរូបវន្តបុគ្គលប៉ុណ្ណោះទេ តែថែមទាំងបានចាត់ទុកមតិយោបល់ទាំងឡាយណាដែលបានបំផ្លាញកិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់ស្ថាប័នជាបទល្មើសផងដែរ។ បទបរិហារកេរ្តិ៍ បានអមជាមួយនឹងបទល្មើសផ្សេងៗជាច្រើនទៀតក្នុងក្រមព្រហ្មទណ្ឌ បានកាត់បន្ថយនូវសិទ្ធិសេរីភាពបញ្ចេញមតិ។ **មាត្រា ៥០២** ចែងពីការផ្តន្ទា

---

[4] យន់ សាមៀន "ហ៊ុន សែន ៖ បទបរិហារកេរ្តិ៍គួរតែដកចេញពីបទល្មើសព្រហ្មទណ្ឌ" សារព័ត៌មាន ឌឹ ខេមបូឌា ដេលី ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៦ និង "នាយករដ្ឋមន្ត្រីសន្យាថាដកបទបរិហារកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌ" អ្នកសារព័ត៌មានគ្មានព្រំដែន ថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០០៦ អាចអានបាន៖ http://en.rsf.org/cambodia-prime-minister-promises-to-07-03-2006,16180.html ។

[5] ការដកចេញការដាក់ពន្ធនាគារគឺលទ្ធផលដ៏ធំធេងនៃការតស៊ូមតិ និងយុទ្ធនាការនៃសម្ព័ន្ធភាពដើម្បីសេរីភាពបញ្ចេញមតិនៅកម្ពុជា (អាហ្វិក) ដែលបង្កើតនិងដឹកនាំដោយ លោក អ៊ូ វីរៈ ប្រធាន ម.ស.ម.ក ។

[6] ប្រហែលជា ៤,០០០រៀល ស្មើនឹង មួយដុល្លារ។

[7] ម.ស.ម.ក "ក្រមព្រហ្មទណ្ឌ សេរីភាពបញ្ចេញមតិកំពុងស្ថិតក្នុងគ្រោះថ្នាក់" ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩ អាចអានបាន ៖ http://www.cchrcambodia.org/admin/media/press_release/press_release/english/2009-10-16.pdf ។

[8] មាត្រា ១៩ "អនុសាសន៍លើសេចក្តីព្រាងក្រមព្រហ្មទណ្ឌ" ខែកញ្ញា ឆ្នាំ២០០៩ អាចអានបាន ៖ http://www.article19.org/pdfs/analysis/cambodia-comment-on-the-draft-penal-code.pdf ។

ទោសដោយដាក់ពន្ធនាគារចំពោះបុគ្គលណាដែលមានវាចា កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់ សេចក្តីថ្លៃថ្នូររបស់មន្ត្រីរាជការ សាធារណៈ ឬ "*ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត*" ខណៈពេលដែល **មាត្រា ៥២៣** ក៏បានចាត់ទុកការរិះគន់ទាំងឡាយ មកលើសេចក្តីសម្រេចរបស់តុលាការ ក្នុងគោលដៅ "*បង្កភាពភ័ីវដល់សណ្តាប់ធ្នាប់សាធារណៈ*" ឬ "*បង្កគ្រោះថ្នាក់ដល់ស្ថាប័ន*" នៅកម្ពុជា ជាបទល្មើសផងដែរ។ បទប្បញ្ញត្តទាំងនេះ ផ្ទុយនឹងបទដ្ឋានអន្តរជាតិដែលទទួលស្គាល់ពីសារៈសំខាន់នៃការរិះគន់ដោយបើកចំហរមកលើ រដ្ឋាភិបាល និងមន្ត្រីសាធារណៈ ក្នុងសង្គមប្រជាធិបតេយ្យ និងហាមឃាត់មិនឲ្យស្ថាប័នសាធារណៈអាចដាក់ពាក្យបណ្តឹងស្តីពីបទបរិហារកេរ្តិ៍ នោះទេ។[9] ឧទាហរណ៍ គោលការណ៍ ស៊ីរ៉ាឃ្យូសា (the Siracusa Principles) ស្តីអំពី បទប្បញ្ញត្តការដាក់កំហិត និងបដិប្បញ្ញត្ត ក្នុង ក.អ.ស.ព.ន បានចែងក្នុងគោលការណ៍ទី ៣៧ ថា "*ការដាក់កំហិតសិទ្ធិមនុស្សដោយផ្អែកលើកេរ្តិ៍ឈ្មោះរបស់បុគ្គលដទៃមិនគួរត្រូវបានប្រើ ដើម្បីការពាររដ្ឋ ឬមន្ត្រីសាធារណៈពីគំនិត ឬការរិះគន់ជាសាធារណៈនោះទេ*" ។[10] មួយវិញទៀត មាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញ បានចែងពីសិទ្ធិ ជាក់លាក់ក្នុងការបរិហារនូវរាល់ការរំលោភបំពានច្បាប់ ទោះជាតាមរយៈសារព័ត៌មាន ឬការបញ្ចេញមតិដទៃទៀត មាត្រានេះបានចែងថា "*ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់ អង្គការសង្គម ឬរបស់បុគ្គលិកនៃអង្គការទាំងនោះ*" ។

មាត្រា ៥០២ និង **៥២៣** ក្នុងក្រមព្រហ្មទណ្ឌ ដូចជារំលោភលើសិទ្ធិដែលបានចែងក្នុងមាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញ ដូច្នេះអាច និយាយបានថាមាត្រាទាំងនេះគ្មានធម្មនុញ្ញភាព។ បទប្បញ្ញត្តគាបសង្កត់ក្នុងក្រមព្រហ្មទណ្ឌបានលើកឡើងថា គោលបំណងចម្បងគឺ ដើម្បី ធានាថាបុគ្គលកាន់អំណាចទាំងអស់ត្រូវបានការពារពីការរិះគន់ ចំណែកអ្នកដែលគ្មានអំណាច គួរតែគិតឲ្យបានច្បាស់មុននឹងបញ្ចេញគំនិត ប្រឆាំងរដ្ឋាភិបាល ឬគណបក្សប្រជាជនកម្ពុជា។ ក្នុងប្រសាសន៍របស់ លោក ខៀវ កាញ៉ារីទ្ធិ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ផ្តល់យោបល់ចំពោះការ អនុម័តក្រមព្រហ្មទណ្ឌថា "*កាលពីមុន ដោយសំអាងលើ "សេរីភាពបញ្ចេញមតិ" និងសមាសភាពជាគណបក្សប្រឆាំង ជនមួយចំនួនអាចដេរ បុគ្គល ឬស្ថាប័នណាក៏បាន។ ប៉ុន្តែពេលនេះមិនអាចធ្វើបែបបនោះបានទេ*" ។[11]

មាត្រា ១២ នៃក្រមព្រហ្មទណ្ឌ ចែងថាវិសាលភាពរបស់ក្រមព្រហ្មទណ្ឌគឺនៅក្នុងប្រទេសកម្ពុជា "*ទឹកដីរបស់កម្ពុជារួមបញ្ចូល ទាំងលំហអាកាស និងសមុទ្រ*" ។ ប៉ុន្តែ **មាត្រា ១៧** ចែងថាក្រមព្រហ្មទណ្ឌអាចប្រើប្រាស់បានចំពោះ "*បុគ្គលគ្រប់រូបដែលជាអ្នកផ្តើមគំនិត ឬ អ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរដូច ខាងក្រោមនេះត្រូវបានបំពេញ ៖*

១. បទល្មើសត្រូវផ្តន្ទាតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេសផងដែរ និង

២. អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស" ។

ន័យមួយទៀត ប្រសិនបើស្ថាប័ន ឬបុគ្គលត្រូវបានផ្តន្ទាទោសពីបទញុះញង់ ឬជួយសម្រួលឲ្យមានការប្រព្រឹត្តបទល្មើសនៅក្រៅ ប្រទេសដែលជាបទឧក្រិដ្ឋ[12] ឬ បទមជ្ឈិម[13] នៅកម្ពុជា ការញុះញង់ ឬការសមគំនិតទាំងនោះនឹងអាចត្រូវបានផ្តន្ទាទោសក្នុងប្រទេស កម្ពុជាផងដែរ ដោយយោងតាមក្រមព្រហ្មទណ្ឌ។ ពាក់ព័ន្ធនឹងបទល្មើសនៃសេរីភាពបញ្ចេញមតិ ចំពោះបទបរិហារកេរ្តិ៍ (**មាត្រា ៣០៦**) ការ

---

[9] មាត្រា ១៩ "របាយការណ៍សង្ខេប ស្តីពីបទដ្ឋានបទបរិហារកេរ្តិ៍អន្តរជាតិ និងបែបប្រៀបធៀប" ខែកុម្ភៈ ឆ្នាំ២០០៤ ទំព័រ ៦-៧ អាចអានបាន ៖ http://www.article19.org/data/files/pdfs/analysis/defamation-standards.pdf ។

[10] គណៈកម្មាការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ "គោលការណ៍ស៊ីរ៉ាឃ្យូសាស្តីពី បទប្បញ្ញត្តការដាក់កំហិត និងបដិប្បញ្ញត្តិក្នុងកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៨៤ E/CN.៤/១៩៨៥/៤ អាចអានបាន ៖ http://www.unhcr.org/refworld/docid/4672bc122.html ។

[11] អង្គការឃ្លាំមើលសិទ្ធិមនុស្ស "កម្ពុជា៖ ក្រមព្រហ្មទណ្ឌថ្មីកាត់បន្ថយសេរីភាពបញ្ចេញមតិ" ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០ អាចអានបាន ៖ http://www.hrw.org/en/news/2010/12/22/cambodia-new-penal-code-undercuts-free-speech ។

[12] បទឧក្រិដ្ឋ គឺជាបទល្មើសកម្រិតធ្ងន់ ដែលមានការផ្តន្ទាទោសដោយការដាក់ពន្ធនាគារក្នុងរយៈពេលលើសពី ៥ឆ្នាំ (**មាត្រា ៤៦**)។ បទល្មើសបរិហារកេរ្តិ៍ផ្ទាល់ មិនមានលក្ខណៈជាបទឧក្រិដ្ឋនោះទេ។

[13] បទមជ្ឈិម ត្រូវបានផ្តល់និយមន័យថាជាបទល្មើសដែលមានការផ្តន្ទាទោសអតិបរមាឲ្យជាប់ពន្ធនាគារលើសពី៦ថ្ងៃ តែតិចជាង ៥ឆ្នាំ (**មាត្រា ៤៧**) ។

ជេរប្រមាថជាសាធារណៈ (**មាត្រា៣០៧**) ឬការជេរប្រមាថមន្ត្រីសាធារណៈ (**មាត្រា ៥០២**) នឹងមិនអាចធ្វើការចោទប្រកាន់នោះទេ ដោយសារតែបទល្មើសទាំងនោះចាត់ទុកត្រឹមតែជា "បទលហុ" ប៉ុណ្ណោះ។[14] ប៉ុន្តែ ដូចបានរៀបរាប់ខាងលើ នឹងអាចមានការចោទប្រកាន់ ចំពោះបទល្មើសដែលស្មើនឹង "បទមជ្ឈិម" ដែលរួមមានការបរិហារបង្កាច់កេរ្តិ៍ (**មាត្រា ៣១១** និង **៣១២**) បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬនាំឲ្យមានការរើសអើង (**មាត្រា ៤៩៥** និង **៤៩៦**) ឬបទល្មើសដែលពាក់ព័ន្ធនឹងសេចក្តីសម្រេច និងការស៊ើបអង្កេតរបស់តុលាការ (**មាត្រា ៥២២** ដល់ **៥២៤**) ។

មាត្រា ១៩ នៃក្រមព្រហ្មទណ្ឌចែងថា ប្រជាពលរដ្ឋកម្ពុជាអាចនឹងត្រូវផ្តន្ទាទោស និងការកាត់ទោសយោងតាមក្រមព្រហ្មទណ្ឌ ប្រសិនបើពួកគេប្រព្រឹត្តបទមជ្ឈិមនៅបរទេស ដែលអំពើនោះជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ជាតិរបស់ប្រទេសនោះផងដែរ។ អំពើនៃការបរិហារបង្កាច់កេរ្តិ៍ ការញុះញង់ឲ្យប្រព្រឹត្តបទល្មើស ឬឲ្យមានការរើសអើង ឬបទល្មើសដទៃទៀតដែលពាក់ព័ន្ធនឹងសេចក្តីសម្រេច ឬការស៊ើបអង្កេតរបស់តុលាការ ដែលជាបទមជ្ឈិមក៏ត្រូវចាត់ឲ្យចូលក្នុងចំណាត់ថ្នាក់នេះផងដែរ។ មួយវិញទៀត **មាត្រា ២២** បានចែងថាក្រមព្រហ្មទណ្ឌរបស់កម្ពុជា អាចអនុវត្តបានចំពោះបទល្មើសទាំងឡាយណាដែលប្រព្រឹត្តនៅក្រៅប្រទេសកម្ពុជា ប្រសិនបើបទល្មើសទាំងនោះអាចចាត់ទុកជាបទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃប្រទេសកម្ពុជា បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុល ឬទីតាំងទូត ឬក៏បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ។

មាត្រា ៤២ នៃក្រមព្រហ្មទណ្ឌបានបញ្ជាក់ថា ក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និង/ឬ បទដ្ឋានគតិយុត្តដទៃទៀត នីតិបុគ្គលអាចត្រូវប្រកាសឲ្យទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយស្ថាប័ន ឬអ្នកតំណាង។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនបានដកទំនួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះសកម្មភាពដូចគ្នានេះទេ។ បទប្បញ្ញត្តនេះ ពាក់ព័ន្ធជាពិសេសជាមួយនឹងអង្គការតស៊ូមតិ សារព័ត៌មាន និងគណបក្សនយោបាយ ព្រោះថាបុគ្គលដែលរងការចោទប្រកាន់នឹងត្រូវទទួលខុសត្រូវ ដោយមិនគិតពីការចោទប្រកាន់ណាមួយមកលើនីតិបុគ្គលផ្ទាល់នោះទេ។ **មាត្រា ១៨** នៃក្រមព្រហ្មទណ្ឌចែងថា *"ការជាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជា បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ត្រូវកំណត់ដោយទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល"* ។

ក្រមព្រហ្មទណ្ឌបង្កើតឲ្យមាន "ការលើកលែង" ចំពោះការអនុវត្តន៍ការផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌ ក្នុងករណីដែលសារព័ត៌មានត្រូវរងការចោទប្រកាន់ពីបទល្មើសបរិហារកេរ្តិ៍ជាក់លាក់ណាមួយ។ **មាត្រា ៣០៦ ៣០៨** និង **៤៩៧** នៃក្រមព្រហ្មទណ្ឌចែងថា ការបរិហារកេរ្តិ៍ និងការជេរប្រមាថជាសាធារណៈ ដែលប្រព្រឹត្តតាមបណ្តាញផ្សព្វផ្សាយព័ត៌មាន និងការញុះញង់ ដែលប្រព្រឹត្តតាមការសែត នឹងត្រូវបានកាត់ទោសដោយប្រើច្បាប់ស្តីពីរបបសារព័ត៌មាន រួមទាំងសំណងផ្នែករដ្ឋប្បវេណីមាននៅក្នុងច្បាប់ស្តីពីរបបសារព័ត៌មានផងដែរ ក៏ប៉ុន្តែ ត្រូវចាំមើលថាបទប្បញ្ញត្តទាំងនោះអាចអនុវត្តបានតាមជាក់ស្តែងដោយរបៀបណា (សូមអានផ្នែកនៃច្បាប់ស្តីពីរបបសារព័ត៌មានខាងក្រោម)។

បទប្បញ្ញត្តចម្បងៗក្នុងក្រមព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងបទបរិហារកេរ្តិ៍ និងបទល្មើសស្រដៀងគ្នាបានកំណត់ក្នុងតារាងខាងក្រោម៖

ការផ្តន្ទាទោសព្រហ្មទណ្ឌដែលអនុវត្តក្នុងក្រមព្រហ្មទណ្ឌ			
បទល្មើស	**មាត្រា**	**ទោសទណ្ឌ**	**ការការពារ**
បរិហារកេរ្តិ៍	**មាត្រា៣០៥**	ពិន័យជាប្រាក់ ១០០,០០០ ទៅ ១០ លានរៀល	**មាត្រា ៣៥** និង **៣៦** ក្នុងក្រមព្រហ្មទណ្ឌ បានចែងពី "ភាពចាំបាច់" និង "កម្លាំង ឬការបង្ខំ" ដែលការពារបទល្មើសបរិហារកេរ្តិ៍ទាំងអស់ ក្នុងក្រមព្រហ្មទណ្ឌ។ ការអនុវត្តន៍នៃការការពារទាំងពីរនេះមានការ
ជេរប្រមាថជាសាធារណៈ	**មាត្រា៣០៧**	ពិន័យជាប្រាក់ ១០០,០០០ ទៅ ១០លានរៀល	
ទោសបន្ថែមចំពោះបទបរិហារកេរ្តិ៍ និងការជេរប្រមាថ	**មាត្រា៣១០**	• ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស • ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសក្នុងសារព័ត៌មាន និង • ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយ	

[14] បទលហុ គឺជាបទល្មើសដែលការផ្តន្ទាទោសអតិបរមាឲ្យជាប់ពន្ធនាគាររយៈពេលក្រោម ឬស្មើ ៦ថ្ងៃ ឬត្រូវបានផ្តន្ទាទោសត្រឹមតែបង់ប្រាក់ពិន័យតែប៉ុណ្ណោះ (**មាត្រា ៤៨**) ។

		ទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ថ្ងៃ យ៉ាងច្រើន។	កំហិតធ្ងន់ធ្ងរណាស់។
ប្តឹងបរិហារបង្កាច់កេរ្តិ៍	**មាត្រា ៣១១** និង **៣១២** ទោសបន្ថែមក្នុងមាត្រា **៣១៣**	ជាប់ពន្ធនាគារចាប់ពី ១ខែ ទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី១០០,០០០ ទៅ ២លានរៀល ទោសបន្ថែម ៖ • ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ខែ យ៉ាងច្រើន • ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសក្នុងសារព័ត៌មាន • ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ថ្ងៃ យ៉ាងច្រើន និង • ក្នុងករណីប្រជានបទនៃបទបរិហារបង្កាច់កេរ្តិ៍នេះ ឈានដល់ការផ្តន្ទាទោសព្រហ្មទណ្ឌ សកម្មភាពដែលបង្កឲ្យមានបទល្មើសគួរតែពន្យារពេលរហូតទាល់តែបញ្ចប់សវនាការ។ **កំណត់សម្គាល់** ៖ ការកំណត់អាជ្ញាយុកាល ក្នុង **មាត្រា ៣១២** បានកំណត់អាជ្ញាយុកាលដែលបទល្មើសអាចនឹងត្រូវបានផ្តន្ទាទោស គឺមានរយៈពេល ១ឆ្នាំបន្ទាប់ពីបណ្តឹងព្រហ្មទណ្ឌ។	**កំណត់សម្គាល់** ៖ ការការពារនេះគឺមិនអាចអនុវត្តបានចំពោះបទបរិហារកេរ្តិ៍ ការញុះញង់ ឬការជេរប្រមាថ លើកលែងតែក្នុងលក្ខខណ្ឌដែលអំពើទាំងនោះ៖ បានប្រព្រឹត្តក្រោមលក្ខខណ្ឌមានការបង្ខិតបង្ខំទាំងផ្នែករូបរាងកាយ និងផ្នែកស្មារតី។ បទបរិហារកេរ្តិ៍ប្រព្រឹត្តដោយគ្មានឥទ្ធិពលពីកត្តាខាងក្រៅ គឺនៅក្រោមការគ្រប់គ្រងរបស់អ្នកប្រព្រឹត្តអំពើនោះ ហើយដូច្នេះនឹងមិនត្រូវបានចាត់ទុកថាជាអំពើប្រព្រឹត្តក្រោមអនុភាពនៃកម្លាំង ឬការបង្ខំនោះទេ។
ការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ[15]	**មាត្រា ៤៩៥**	អនុវត្តចំពោះករណីដែលមានការញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬឲ្យប្រព្រឹត្តអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ដល់សន្តិសុខសង្គម ចំពោះករណីដែលការញុះញង់នោះគ្មានប្រសិទ្ធភាព៖ ត្រូវជាប់ពន្ធនាគារពី ៦ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ១លាន ទៅ៤លានរៀល។ **កំណត់សម្គាល់** ៖ គ្មានបទប្បញ្ញត្តដាក់ទោសនៅក្នុងក្រមព្រហ្មទណ្ឌចំពោះករណីដែលការញុះញង់មានប្រសិទ្ធភាពនោះទេ។	
ញុះញង់ឲ្យមានការរើសអើង	**មាត្រា ៤៩៦**	ការញុះញង់ឲ្យមានការរើសអើង ក្នុងករណីដែលការញុះញង់នោះគ្មានប្រសិទ្ធភាព ៖ ត្រូវជាប់ពន្ធនាគារពី១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លាន ទៅ ៦លានរៀល។ **កំណត់សម្គាល់** ៖ គ្មានបទប្បញ្ញត្តដាក់ទោសនៅក្នុងក្រមព្រហ្មទណ្ឌចំពោះករណីដែលការញុះញង់មានប្រសិទ្ធភាពនោះទេ។	
ទោសបន្ថែមសម្រាប់បទល្មើសញុះញង់	**មាត្រា ៤៩៨**	• ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើន[16] • ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធជាតិផ្ទុះ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើន	

[15] **មាត្រា ៤៩៤** នៃក្រមព្រហ្មទណ្ឌចែងថាការញុះញង់ទាំងអស់ (**មាត្រា ៤៩៥** និង **៤៩៦**) នឹងត្រូវបានផ្តន្ទាទោស កាលបើអំពើនេះត្រូវបានប្រព្រឹត្ត ៖

1. *"ដោយសម្តីតាមប្រភេទណាក៏ដោយ ដែលប្រកាសនៅក្នុងទីសាធារណៈ ឬក្នុងពេលប្រជុំជាសាធារណៈ*
2. *ដោយសំណេរ ឬគំនូរ តាមប្រភេទណាក៏ដោយ ដែលត្រូវផ្សព្វផ្សាយ នៅចំណោមសាធារណជន ឬតាំងឲ្យសាធារណជនមើល ឬ*
3. *ដោយគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន។"*

[16] សិទ្ធិពលរដ្ឋដែលអាចដកហូតមានកំណត់ក្នុង **មាត្រា ៥៥**។ សិទ្ធិទាំងនោះរួមមានសិទ្ធិ ៖ បោះឆ្នោត ឈរឈ្មោះឲ្យបោះឆ្នោត បំពេញការងារជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈ ទទួលចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្តាល ឬជាអាណត្តិគាហកបស់តុលាការ ទទួល និងពាក់គ្រឿងឥស្សរិយសទាំងអស់ ធ្វើសាក្សីដែលទទួលសម្បថនៅមុខតុលាការ។ តែសិទ្ធិទាំងនោះមិនរួមបញ្ចូលនូវសេរីភាពមូលដ្ឋានដូចជាសិទ្ធិសេរីភាពបញ្ចេញមតិ ជាដើម។

		• ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ខែ យ៉ាងច្រើន • ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសក្នុងសារព័ត៌មាន និង • ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ថ្ងៃ យ៉ាងច្រើន។	
ការជេរប្រមាថ (សំដៅលើអ្នករាជ-ការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោតក្នុងក្របខណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញការងាររបស់ខ្លួន)[17]	**មាត្រា ៥០២** ទោសបន្ថែមក្នុង **មាត្រា ៥០៧**	ត្រូវជាប់ពន្ធនាគារពី ១ថ្ងៃ ទៅ ៦ថ្ងៃ និងពិន័យជាប្រាក់ពី ១,០០០ ទៅ ១០០,០០០ រៀល។ ទោសបន្ថែម • ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើន • ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ខែ យ៉ាងច្រើន • ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសក្នុងសារព័ត៌មាន និង • ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ថ្ងៃ យ៉ាងច្រើន។	
បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ	**មាត្រា ៥២២**	ត្រូវជាប់ពន្ធនាគារពី ១ ទៅ ៦ខែ និងពិន័យជាប្រាក់ពី ១០០,០០០ ទៅ ១លានរៀល **កំណត់សម្គាល់ ៖ មាត្រា ៥២៥** ចែងថាការប៉ុនប៉ងប្រព្រឹត្តអំពើដែលបានរៀបរាប់ក្នុង **មាត្រា ៥២២** ដល់ **៥២៤** នឹងត្រូវផ្តន្ទាទោសដូចគ្នានឹងការប្រព្រឹត្តបទល្មើសដែរ។	
បទធ្វើឲ្យបាត់ជំនឿទុកចិត្តលើសេចក្តីសម្រេចរបស់តុលាការ	**មាត្រា ៥២៣**		
បទប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ	**មាត្រា ៥២៤**		
ទោសបន្ថែមសម្រាប់មាត្រា **៥២២** ដល់ **៥២៤**	**មាត្រា ៥២៦**	• ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើន[18] • ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះ	

[17] *"អង្គហេតុដែលសេរីភាពបញ្ចេញមតិតែងតែត្រូវបានចាត់ទុកថាជាការជេរប្រមាថដល់បុគ្គលសាធារណៈ គឺមិនគ្រប់គ្រាន់សម្រាប់ជាមូលហេតុក្នុងការផ្តន្ទាទោសនោះទេ ទោះបីជាបុគ្គលសាធារណៈក៏អាចទទួលប្រយោជន៍ពីបញ្ញត្តក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ។ ម្យ៉ាងវិញទៀត បុគ្គលសាធារណៈទាំងអស់ រួមទាំងអ្នកដែលអនុវត្តសមត្ថកិច្ចនយោបាយជ័ខ្ពស់បំផុត ដូចជា ប្រមុខរដ្ឋ និងរដ្ឋាភិបាល ក៏អាចជាប្រធានបទនៃការរិះគន់ និងការប្រឆាំងផ្នែកនយោបាយដែរ។ ដោយហេតុនេះ គណៈកម្មាធិការសិទ្ធិមនុស្ស បានបញ្ជាក់ពីសេចក្តីព្រួយបារម្ភពាក់ព័ន្ធនឹងច្បាប់ស្តីពីបញ្ហាដូចជា [...] ការមិនគោរពអាជ្ញាធរ [...] បទបរិហារកេរ្តិ៍ចំពោះប្រមុខរដ្ឋ និងការការពារកិត្តិយសរបស់មន្ត្រីសាធារណៈ និងច្បាប់មិនគួរផ្តន្ទាទោសធ្ងន់ធ្ងរដោយផ្អែកតែលើមូលដ្ឋាននៃអត្តសញ្ញាណរបស់បុគ្គលដែលប្រហែលជាត្រូវបានរិះគន់។ ស្ថាប័នរដ្ឋមិនគួរហាមឃាត់ការរិះគន់មកលើស្ថាប័ន ដូចជា កងកម្លាំងយោធា និងរដ្ឋបាល"* ។ (គណៈកម្មាធិការសិទ្ធិមនុស្ស ការផ្តល់យោបល់ទូទៅលេខ ៣៤ អង្គប្រជុំលើកទី១២២ ទីក្រុងសឺណែវ ថ្ងៃទី១១-២៩ ខែកក្កដា ឆ្នាំ២០១១ (CCPR/C/GC/៣៤) កំណត់សម្គាល់ទូទៅលេខ៣៤) ។

[18] សូមអានកំណត់សម្គាល់លេខ ១៦ ខាងលើ។

		បានប្រព្រឹត្តក្នុងអំឡុងពេលនៃការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្តាពរ ឬសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើន[19] • ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស[20] • ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្តាពរ ឬសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន • ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ខែ យ៉ាងច្រើន • ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសក្នុងសារព័ត៌មាន និង • ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ថ្ងៃ យ៉ាងច្រើន។	
បទប្បញ្ញត្តការផ្តន្ទាទោសរដ្ឋប្បវេណីដែលអនុវត្តក្នុងក្រមព្រហ្មទណ្ឌ			
មិនមានបទប្បញ្ញត្តណាមួយសម្រាប់ការផ្តន្ទាទោសផ្នែករដ្ឋប្បវេណីត្រូវបានអនុវត្តក្នុងក្រមព្រហ្មទណ្ឌនោះទេ។ ការខូចខាត ឬសំណងត្រូវសម្រេចយ៉ាងអត្តនោម័តដោយតុលាការ ផ្អែកលើចំនួននៃការខូចខាត គិតជាចំនួនប្រាក់ ដែលជនរងគ្រោះទទួលផលប៉ះពាល់ដល់កិត្តិយស ឬសេចក្តីថ្លៃថ្នូររបស់ពួកគាត់។ ជំណើរការនៃការផ្តើមបណ្តឹងរដ្ឋប្បវេណីគឺបានកំណត់ក្នុង **មាត្រា ៣០៩** នៃក្រមព្រហ្មទណ្ឌ។[21]			

២. ក្រមព្រហ្មទណ្ឌអន្តរកាល

ក្នុងអំឡុងអាណត្តិរបស់ អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) ចាប់ពីឆ្នាំ ១៩៩១ ដល់ ឆ្នាំ១៩៩៣ ក្រមព្រហ្មទណ្ឌមួយត្រូវបានបង្កើតឡើង ដោយឧត្តមក្រុមប្រឹក្សាជាតិ ដែលមានព្រះអង្គម្ចាស់សីហនុ (បន្ទាប់មកក្លាយជាព្រះមហាក្សត្រ)[22] ជាប្រធានបានអនុម័តលើក្រមនេះ។ ប៉ុន្តែ ការប្រកាសឲ្យប្រើក្រមព្រហ្មទណ្ឌ ក្នុងខែធ្នូ ឆ្នាំ២០១០ មានន័យថា បទប្បញ្ញត្តមួយចំនួនក្នុងក្រមព្រហ្មទណ្ឌអន្តរកាលត្រូវបានជំនួស ទោះបីជា ម.ស.ម.ក សន្មតថាបទប្បញ្ញត្តទាំងនោះនៅតែបន្តត្រូវបានប្រើប្រាស់ ក្នុងករណី (១) បទល្មើសក្នុងក្រមព្រហ្មទណ្ឌអន្តរកាលមិនមានក្នុងក្រមព្រហ្មទណ្ឌ ឬ (២) ក្នុងពេលដែលប្រព្រឹត្តបទល្មើស បទប្បញ្ញត្តក្នុងក្រមព្រហ្មទណ្ឌមិនទាន់ចូលជាធរមាន។

ពាក់ព័ន្ធជាមួយចំណុច (១) ខាងលើ ដោយអវត្តមាននៃភាសាច្បាស់លាស់ក្នុងក្រមព្រហ្មទណ្ឌ មានការសន្មត់ថា ប្រសិនបើបុគ្គលម្នាក់បានប្រព្រឹត្តបទល្មើស ដែលជាបទល្មើសក្នុងក្រមព្រហ្មទណ្ឌ ប៉ុន្តែមិនត្រូវបានបញ្ជាក់ (ឬសរសេរសារឡើងវិញ ឬក៏ត្រូវបានគ្របដណ្តប់)

---

[19] សូមបញ្ជាក់ថា **មាត្រា ៥៦** បានចែងថាការហាមឃាត់មិនបានអនុវត្តចំពោះការបំពេញអាណត្តិដែលជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈ ឬការទទួលខុសត្រូវខាងសហជីពទេ ហើយក៏មិនអាចអនុវត្តចំពោះបទល្មើសរំលោភលើច្បាប់ស្តីពីរបបសារព័ត៌មាននោះទេ។

[20] សូមបញ្ជាក់ថា **មាត្រា ៦២** បានចែងថាការរឹបអូសក៏នឹងត្រូវបានអនុវត្តសម្រាប់សម្ភារៈ ឬក៏មូលនិធិដែលជាកម្មវត្ថុ ឬជាផលកើតចេញពីបទល្មើសផងដែរ។ ច្បាប់នេះក៏ត្រូវបានអនុវត្តចំពោះ "ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុ នៅក្នុងទីកន្លែងដែលបទល្មើសបានបានប្រព្រឹត្ត" ។ សូមបញ្ជាក់ថាការរឹបអូសមិនអាចប្រកាសបានទេ ប្រសិនបើមានការប៉ះពាល់ដល់សិទ្ធិរបស់តតិយជន។

[21] **មាត្រា ៣០៩** បានចែងថាបទល្មើសដែលពាក់ព័ន្ធនឹងការបរិហារកេរ្តិ៍ និងការជេរប្រមាថចំពោះសមាជិករាជរដ្ឋាភិបាល មន្ត្រីរាជការសាធារណៈ ឬពលរដ្ឋដែលទទួលបន្ទុកបេសកកម្មសាធារណៈ ឬអាណត្តិសាធារណៈ ការចោទប្រកាន់នឹងត្រូវធ្វើឡើងតាមបណ្តឹងរបស់សាមីខ្លួន ឬបណ្តឹងរបស់ប្រធានស្ថាប័នសាមី។ នៅពេលដែលមានការបរិហារកេរ្តិ៍ ឬជេរប្រមាថមកលើបុគ្គលឯកជន បុគ្គលនោះគឺជាអ្នកដាក់ពាក្យបណ្តឹង។ ក្នុងករណីទាំងពីរ ការដាក់ពាក្យបណ្តឹងដើម្បីឲ្យមានការវិនិច្ឆយទោសត្រូវបានធ្វើឡើងដោយដើមបណ្តឹងផ្ទាល់ដោយបញ្ជាក់ពីលំនៅដ្ឋានរបស់គាត់ក្នុងខេត្ត ឬក្រុងដែលតុលាការបានទទួលពាក្យបណ្តឹង។ តុលាការនឹងជូនដំណឹងដល់ជនជាប់ចោទ និងព្រះរាជអាជ្ញា។ ការចោទប្រកាន់នឹងធ្វើឡើងដោយស្វ័យប្រវត្តដោយព្រះរាជអាជ្ញា ប្រសិនបើបទបរិហារកេរ្តិ៍ ឬការជេរប្រមាថត្រូវបានធ្វើឡើងប្រឆាំងនឹងបុគ្គលម្នាក់ អាស្រ័យលើដើមកំណើត ជាតិពន្ធុ ពូជសាសន៍ សញ្ជាតិ ឬសាសនារបស់បុគ្គលនោះ។

[22] ឋានៈរបស់សម្តេចសីហនុកាលពីមួយទសវត្សរ៍មុន។

នៅក្នុងក្រមព្រហ្មទណ្ឌ តាមទ្រឹស្តី បុគ្គលម្នាក់នោះអាចនឹងត្រូវបានកាត់ទោសដោយប្រើក្រមព្រហ្មទណ្ឌអន្តរកាល ដោយសារតែបទល្មើសឬបទប្បញ្ញត្តដែលសំដៅដល់នេះមិនទាន់ត្រូវបាននិរាករណ៍ ព្រោះថាក្រមព្រហ្មទណ្ឌអន្តរកាលក៏មិនទាន់ត្រូវបាននិរាករណ៍ដូចគ្នា។ ការអះអាងនេះគឺផ្អែកទៅលើគោលការណ៍គតិយុត្ត ដែលកំណត់ថាប្រសិនបើច្បាប់មិនទាន់ត្រូវបាននិរាករណ៍ដោយបើកចំហរ[23] ឬក៏ត្រូវបាននិរាករណ៍ដោយប្រយោល ដោយសារតែមានទំនាស់ជាមួយនឹងបញ្ញត្តច្បីជាង នោះច្បាប់នោះនៅតែអាចអនុវត្តបាននៅឡើយ។

តាមរយៈ (២) ខាងលើ មាត្រា ៦៧១ នៃក្រមព្រហ្មទណ្ឌ ចែងថាសំណុំរឿងគួរតែត្រូវបានពិនិត្យដោយផ្អែកលើក្រមព្រហ្មទណ្ឌដែលចូលជាធរមានក្នុងខណៈពេលប្រព្រឹត្តបទល្មើស ដូចជា ក្រមព្រហ្មទណ្ឌអន្តរកាល (ក្នុងករណីនេះ)។ បន្ថែមពីលើនោះ មាត្រា៥ នៃក្រមព្រហ្មទណ្ឌបញ្ជាក់ថា "*ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ*" ។ ចំណុចទីពីរគឺច្បាស់លាស់ណាស់ ៖ គ្មាននរណាអាចនឹងត្រូវបានកាត់ទោសចំពោះបទល្មើសដែលមិនទាន់កើតមានក្នុងខណៈពេលដែល គេប្រព្រឹត្តអំពើនេះនោះទេ។

តាមរយៈឧទាហរណ៍ បទល្មើស "ផ្តល់ព័ត៌មានមិនពិត" ជាបញ្ញត្តពីក្រមព្រហ្មទណ្ឌអន្តរកាល ដែលកាលពីមុនត្រូវបានប្រើប្រាស់ជាញឹកញាប់ដោយរដ្ឋាភិបាល ដើម្បីបំបិទសំឡេងប្រឆាំង (សូមអានករណីសិក្សាលោក សម រង្ស៊ី ខាងក្រោម) នៅតែបន្តយកមកអនុវត្ត ថ្វីបើច្បាប់នេះមិនត្រូវបានបញ្ចូលក្នុងក្រមព្រហ្មទណ្ឌក៏ដោយ ពីព្រោះបញ្ញត្តនេះមិនទាន់ត្រូវបាននិរាករណ៍ដោយបើកចំហរនៅឡើយ។ ប៉ុន្តែ យើងឃើញមានការអនុវត្តច្បាប់ដោយខុសក្នុងសំណុំរឿងមួយចំនួន ៖ កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១២ សាលាឧទ្ធរណ៍កម្ពុជា បានសម្រេចតម្កល់ការផ្តន្ទាទោសជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ របស់បុគ្គលិក នៃសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ លោក លាង សុខជឿន ប៉ុន្តែបានប្តូរបទចោទប្រកាន់ពីបទផ្តល់ព័ត៌មានមិនពិតក្នុង **មាត្រា ៦២** នៃក្រមព្រហ្មទណ្ឌអន្តរកាល ដែលកាត់ទោសដោយតុលាការខេត្តតាកែវ កាលពីខែសីហា ឆ្នាំ២០១០ (មុនពេលក្រមព្រហ្មទណ្ឌចូលជាធរមាន) មកជាបទញុះញង់ក្នុង មាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌវិញ។[24] ការផ្តន្ទាទោសបុគ្គលចំពោះបទល្មើសដែលបានប្រព្រឹត្ត មុនពេលបទល្មើសនោះចូលជាធរមានគឺផ្ទុយនឹងគោលការណ៍គតិយុត្ត និងរំលោភសិទ្ធិចុងចោទ គឺសិទ្ធិដឹងពីចរិតលក្ខណៈ និងមូលហេតុនៃការដាក់ពាក្យបណ្តឹងប្រឆាំងនឹងខ្លួនផងដែរ។[25] ដោយសារ តែពេលនេះក្រមព្រហ្មទណ្ឌចូលជាធរមាន ចំណុចទី (២) ខាងលើនឹងកាន់តែមិនសូវពាក់ព័ន្ធក្នុងពេលអនាគត ទោះបីជាករណីរបស់ លោក លាង សុខជឿន បានបង្ហាញថា តុលាការបានអនុវត្តច្បាប់ទាំងមិនត្រឹមត្រូវដើម្បីជំរុញដល់ការបង្ក្រាបមកលើសេរីភាពបញ្ចេញមតិនៅកម្ពុជាក៏ដោយ។ ករណីនេះគឺជាករណីទីពីរ ដែលបានប្តូរបទចោទប្រកាន់ពីបទផ្តល់ព័ត៌មានមិនពិត ក្នុងក្រមព្រហ្មទណ្ឌអន្តរកាល មកជាបទញុះញង់ក្នុងក្រមព្រហ្មទណ្ឌ ចំណែកករណីមួយទៀតគឺ ករណី លោក មឿង សុន ប្រធាន មូលនិធិទ្រទ្រង់អរិយធម៌ខ្មែរ។

ប៉ុន្តែ មាត្រា ១០ នៃក្រមព្រហ្មទណ្ឌ បានកំណត់ការអនុវត្តប្រតិសកម្មនៃច្បាប់ឲ្យមានភាពស្របច្បាប់ ចំពោះការផ្តន្ទាទោសក្នុងបញ្ញត្តក្រមព្រហ្មទណ្ឌ ដែលការផ្តន្ទាទោសអតិបរមាក្នុងក្រមព្រហ្មទណ្ឌ មិនសូវធ្ងន់ធ្ងរដូចជាការផ្តន្ទាទោសក្នុងក្រមព្រហ្មទណ្ឌអន្តរកាលចំពោះបទល្មើសដូចគ្នា។ ប្រសិទ្ធភាពនៃមាត្រានេះគឺ តុលាការអាចប្រើប្រាស់បទប្បញ្ញត្តក្នុងក្រមព្រហ្មទណ្ឌមកផ្តន្ទាទោសលើបុគ្គល ចំពោះបទល្មើសដែលបានប្រព្រឹត្តមុនពេលបញ្ញត្តក្រមព្រហ្មទណ្ឌចូលជាធរមាន សម្រាប់បទចោទប្រកាន់ក្នុងក្រមព្រហ្មទណ្ឌអន្តរកាល ប៉ុន្តែអាចអនុវត្តបានក្នុងករណីដែលការផ្តន្ទាទោសអតិបរមាក្នុងក្រមព្រហ្មទណ្ឌ មិនធ្ងន់ធ្ងរដូចការផ្តន្ទាទោសក្នុងក្រមព្រហ្មទណ្ឌអន្តរកាល ហើយនៅពេលដែលបទល្មើសដែលស្ថិតក្នុងច្បាប់ទាំងពីរនេះដូចគ្នា ឬមានកម្រិតស្មើគ្នា ឧ.បទញុះញង់។ ករណីដែលចំណុចទី (២) ខាងលើអាចអនុវត្តបាន គួរតែមានការប្រុងប្រយ័ត្នក្នុងកម្រិតមួយជាក់លាក់ ព្រោះថាអាចនឹងមានការយល់ច្រលំមិនច្បាស់ថាតើគួរប្រើច្បាប់ណាដើម្បីផ្តន្ទាទោស។

---

[23] ដូចដែលបានប្រមើលមើលក្នុង មាត្រា ៩ នៃក្រមព្រហ្មទណ្ឌ ដែលចែងថា "បញ្ញត្តច្បីដែលលុបចោលនូវបទល្មើសគឺអាចអនុវត្តបានភ្លាមៗ។ អំពើដែលប្រព្រឹត្តមុនពេលថ្ងៃកំណត់ដែលមានសុពលភាពនឹងមិនត្រូវបានយកមកកាត់ទោសនោះទេ។

[24] សម្រាប់ព័ត៌មានបន្ថែម សូមអាន សេចក្តីថ្លែងការព័ត៌មាន ដោយលីកាដូ កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ ដែលមានចំណងជើងថា "សាលាឧទ្ធរណ៍តម្កល់សេចក្តីសម្រេចដែលគ្មានមូលដ្ឋានប្រឆាំងនឹង បុគ្គលិកអង្គការ លីកាដូ" ។

[25] មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

ក្រមព្រហ្មទណ្ឌអន្តរកាលមិនមានការបញ្ជាក់ ឬបទប្បញ្ញត្តណាមួយពាក់ព័ន្ធនឹងវិសាលភាពនៃយុត្តាធិការទេ ទោះបីជាក្នុងបរិបទបានបង្ហាញយ៉ាងច្បាស់លាស់ថា ក្រមនេះមានបំណងប្រើជាក្រមព្រហ្មទណ្ឌបណ្តោះអាសន្នក្នុងសម័យអ៊ុនតាក់ មុនពេលមានការបោះឆ្នោតហើយកាល:ទេស:មួយចំនួន គឺមុនពេលក្រមព្រហ្មទណ្ឌថ្មី និងមានអាយុកាលវែងត្រូវបានអនុម័ត។

បទប្បញ្ញត្តចម្បងៗក្នុងក្រមព្រហ្មទណ្ឌអន្តរកាលដែលពាក់ព័ន្ធនឹងបទបរិហារកេរ្តិ៍ និងបទល្មើសស្រដៀងគ្នាបានកំណត់ក្នុងតារាងខាងក្រោម ៖

ការផ្តន្ទាទោសព្រហ្មទណ្ឌដែលត្រូវបានអនុវត្តក្នុងក្រមព្រហ្មទណ្ឌអន្តរកាល			
បទល្មើស	**មាត្រា**	**ការផ្តន្ទាទោស**	**ការការពារ**
ការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋដោយបានសម្រេចផល	**មាត្រា ៥៩**	• ត្រូវជាប់ពន្ធនាគារ រយៈពេលគឺអាស្រ័យលើប្រភេទនៃបទល្មើសដែលបានប្រព្រឹត្ត ឬ • ការពិន័យជាប្រាក់ ចំនួនទឹកប្រាក់អាស្រ័យលើប្រភេទនៃបទល្មើសដែលបានប្រព្រឹត្ត	គ្មានការការពារដែលអាចអនុវត្តបានចែងយ៉ាងបើកចំហក្នុងក្រមព្រហ្មទណ្ឌអន្តរកាលនោះទេ
ការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋដោយមិនសម្រេចផល	**មាត្រា ៦០**	ដាក់ពន្ធនាគារពី ១ ទៅ ៥ ឆ្នាំ	
ការញុះញង់ឲ្យមានការរើសអើង	**មាត្រា ៦១**	• ត្រូវជាប់ពន្ធនាគារពី ១ខែ ទៅ ១ឆ្នាំ ឬ • ពិន័យជាប្រាក់ពី ១លាន ទៅ ១០លានរៀល	
ការផ្សាយព័ត៌មានមិនពិត	**មាត្រា ៦២**	• ត្រូវជាប់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ • ពិន័យជាប្រាក់ពី ១លាន ទៅ ១០លានរៀល ឬ • ផ្តន្ទាទោសទាំងពីរប្រភេទ	
ការបរិហារកេរ្តិ៍ និងការជេរប្រមាថ	**មាត្រា ៦៣**	ចំពោះបទបរិហារកេរ្តិ៍ប្រព្រឹត្តតាមរយៈមធ្យោបាយដែលបានរៀបរាប់ក្នុង **មាត្រា ៥៩** ៖ [26] • ពិន័យជាប្រាក់ពី ១លាន ទៅ១០លាន រៀល ឬ • ការបិទផ្សាយសេចក្តីសម្រេចរបស់ខ្លួន នៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ និងបោះពុម្ពផ្សាយលើសារព័ត៌មានមួយ ឬច្រើន ដោយឲ្យជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ (ច្រើនបំផុត ១០លានរៀល)។	
ការផ្តន្ទាទោសផ្នែករដ្ឋប្បវេណីអនុវត្តក្នុងក្រមព្រហ្មទណ្ឌអន្តរកាល			
មាត្រា ២៧(១) នៃក្រមព្រហ្មទណ្ឌអន្តរកាលអនុញ្ញាតឲ្យជនរងគ្រោះ ឬសិទ្ធិវិន្នរបស់ជនរងគ្រោះទាំងឡាយ ដោយផ្ទាល់ ឬតាមរយៈទីប្រឹក្សា អាចតាំងខ្លួនជាភាគីរដ្ឋប្បវេណី នៅពេលអង្កេតស៊ើបសួរ ឬពេលសវនាការជំនុំជម្រះ ដើម្បីទាមសំណងដំងឹចិត្តពីអ្នកប្រព្រឹត្ត ឬដៃគូអ្នកប្រព្រឹត្តបទល្មើស ឬអ្នកសមគំនិតក្នុងបទល្មើស។ **មាត្រា ២៧(២)** ជនប្រព្រឹត្តបទល្មើស និងអ្នកសមគំនិតត្រូវទទួលខុសត្រូវរួម ក្នុងការជួសជុល ឬសងជំងឺចិត្ត ដោយយោងតាម សេចក្តីប្រកាស *ស្តីអំពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌ ទាក់ទិនទៅនឹងជនរងគ្រោះពីបទឧក្រិដ្ឋ និងជនរងគ្រោះពីការរំលោភអំណាច*។ ដូច្នេះ អ្នកដែលរកឃើញថាមានកំហុសក្នុងបទល្មើសព្រហ្មទណ្ឌតាមបទប្បញ្ញត្តក្រមព្រហ្មទណ្ឌ ត្រូវទទួលខុសត្រូវចំពោះសំណងរដ្ឋប្បវេណីផងដែរ។ **មាត្រា ៦១** និង **៦៣** បានចែងថាការទទួលខុសត្រូវរដ្ឋប្បវេណីបន្ថែមទៀត ដូចបានរៀបរាប់ខាងក្រោម។			
ការញុះញង់ឲ្យមានការរើសអើង	**មាត្រា ៦១**	និយោជក អ្នកបោះពុម្ព ក្រុមហ៊ុនបោះពុម្ពផ្សាយ ឬ ក្រុម-ហ៊ុនផ្សព្វផ្សាយ ត្រូវទទួលខុសត្រូវរួមក្នុងការសងជំងឺចិត្ត ផ្សេងៗ ដែលនឹងត្រូវផ្តល់ជូនជនរងគ្រោះម្នាក់ ឬច្រើន	មិនមានការការពារណាដែលអាចអនុវត្តបានក្នុងក្រមព្រហ្មទណ្ឌអន្តរកាលនោះទេ
ការបរិហារកេរ្តិ៍ និងការជេរ	**មាត្រា ៦៣**		

[26] រួមមាន ៖ សម្តី សម្រែក ឬការគំរាមកំហែងក្នុងកន្លែង ឬអង្គប្រជុំសាធារណៈ តាមរយៈសំណេរ ការបោះពុម្ពផ្សាយ គំនូរ ចម្លាក់ វិចិត្រកម្ម និម្មិតរូប ភាពយន្ត ឬគ្រប់ការគាំទ្រនៃការសរសេរ សម្តី ឬភាពយន្តដែលដាក់លក់ ចែកចាយ ឬដាក់តាំងនៅកន្លែងនានា ឬក្នុងអង្គប្រជុំសាធារណៈ ផ្ទាំងបដា ឬប័ណ្ណប្រកាសដែលតាំងឲ្យសាធារណជនឃើញ តាមគ្រប់មធ្យោបាយទំនាក់ទំនងសោតទស្សន៍។

ប្រមាថ		នាក់។ **កំណត់សម្គាល់** ៖ រាល់សមាគមទាំងឡាយណាបង្កើតឡើង អនុលោមតាមការអនុម័តពី ឧត្តមក្រុមប្រឹក្សាជាតិ អាចធ្វើអន្តរាគម និងដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងភាគីចុងចោទនៃសកម្មភាពដែលត្រូវបានគ្របដណ្តប់ដោយមាត្រានេះ តាមរយៈការដាក់ពាក្យប្តឹងដល់ព្រះរាជ-អាជ្ញាដែលមានសមត្ថកិច្ច និងដោយដាក់ញត្តិទៅតុលាការដើម្បីឲ្យមានអន្តរាគម។	

៣. ច្បាប់ស្តីពីរបបសារព័ត៌មាន

គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់ថា "*សារព័ត៌មានសេរី គ្មានការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយ និងគ្មានការរារាំង គឺមានភាពចាំបាច់ក្នុងសង្គមដើម្បីជានាសេរីភាពបញ្ចេញគំនិត និងមតិ និងទទួលបានសិទ្ធិដែលមានចែងក្នុង ក.អ.ស.ព.ន ជាទៃទៀត។ កតិកានេះជាសសរស្តម្ភមួយក្នុងសង្គមប្រជាធិបតេយ្យ*" ។[27]

ច្បាប់ស្តីពីរបបសារព័ត៌មានត្រូវបានដាក់ឲ្យអនុវត្តក្នុងឆ្នាំ ១៩៩៥ ជាមួយនឹងការព្រួយបារម្ភថា មាត្រាជាក់លាក់មួយចំនួនក្នុងច្បាប់នេះ នឹងអាចត្រូវបានប្រើប្រាស់ដើម្បីបំបាត់មតិយោបល់រិះគន់ដោយស្របច្បាប់មកលើគោលនយោបាយ និងសកម្មភាពនយោបាយ ជាតិ និងអន្តរជាតិ របស់រដ្ឋាភិបាល។[28] ទាំងអង្គការសង្គមស៊ីវិល និងសារព័ត៌មានបានធ្វើការរិះគន់បន្ថែមមកលើច្បាប់ស្តីពីរបបសារព័ត៌មាន ដោយផ្អែកលើមូលដ្ឋានមួយថាច្បាប់នេះបានបង្កើនការរារាំងមកលើការបញ្ចេញមតិ នៅពេលដែលបញ្ចេញសំឡេង ឬបោះពុម្ពផ្សាយដោយអ្នកសារព័ត៌មាន។[29] ការដាក់កំហិតបន្ថែមទាំងឡាយណា គឺផ្ទុយនឹងបទប្បញ្ញត្តិក្នុងមាត្រា ១៩ នៃ ក.អ.ស.ព.ន និងបណ្តាលឲ្យមានការរំលោភសិទ្ធិសេរីភាពបញ្ចេញមតិរបស់អ្នកសារព័ត៌មាន និពន្ធនាយក ឬបុគ្គលិកសារព័ត៌មាន ដែលជាសិទ្ធិមូលដ្ឋានរបស់ប្រជាពលរដ្ឋក្នុងសង្គមដែលទទួលបានដោយស្មើភាពក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ (សូមអានផ្នែក "សិទ្ធិសេរីភាពបញ្ចេញមតិ" ខាងលើ)។

ច្បាប់ស្តីពីរបបសារព័ត៌មាន បានធានាយ៉ាងបើកចំហចំពោះសេរីភាពបញ្ចេញមតិសម្រាប់សារព័ត៌មាន ដោយសារតែច្បាប់នេះចែងថា "*កំណត់នូវរបបសារព័ត៌មាន និងធានាសេរីភាពសារព័ត៌មាន និងសេរីភាពនៃការបោះពុម្ពផ្សាយដោយអនុលោមតាមមាត្រា ៣១ និង ៤១ នៃរដ្ឋធម្មនុញ្ញ*" (**មាត្រា ១**)។ ម្យ៉ាងវិញទៀត **មាត្រា ៣** បានចែងពីសិទ្ធិសេរីភាពមិនឲ្យមានការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយ (**មាត្រា ៣**)។ ការបោះពុម្ពផ្សាយព័ត៌មានផ្លូវការ មិនអាចត្រូវបានផ្តន្ទាទោស ប្រសិនបើការផ្សាយនោះមានលក្ខណៈស្របតាមសភាពពិតពេញលេញ ឬសេចក្តីសង្ខេបត្រឹមត្រូវតាមរឿងពិត (**មាត្រា ៤**)។ ប៉ុន្តែ ច្បាប់ស្តីពីរបបសារព័ត៌មាន បានដាក់កម្រិតពាក់ព័ន្ធនឹងចំណុចទាំងឡាយណាដែល "*ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដោយញុះញង់ដោយផ្ទាល់ឲ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើហិង្សា*" (**មាត្រា ១១**) ឬដែល "*អាចបណ្តាលឲ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថិរភាពនយោបាយ*" (**មាត្រា ១២**) ឬដែលប៉ះពាល់ដល់ "*ប្រពៃណីល្អរបស់សង្គម*" (**មាត្រា ១៤**) ។ ចំណុចទាំងនេះនៅមិនទាន់មានភាពច្បាស់លាស់ ហើយដូច្នេះបង្កឲ្យមានបញ្ហាព្រោះថាចំណុចទាំងនេះអាចបណ្តាលឲ្យមានការរំលោភបំពាន និងអាចទទួលទណ្ឌកម្មផ្នែកហិរញ្ញវត្ថុ និងលទ្ធភាពដែលក្រសួងព័ត៌មាន និងក្រសួងមហាផ្ទៃ ព្យួរការបោះពុម្ពផ្សាយក្នុងរយៈពេលមិនលើសពី ៣០ថ្ងៃ ដោយគ្មានសិទ្ធិប្តឹងជំទាស់ យោងតាម **មាត្រា ១២** ។

---

[27] គណៈកម្មាធិការសិទ្ធិមនុស្ស ការផ្តល់យោបល់ទូទៅលេខ ៣៤ អង្គប្រជុំលើកទី១០២ ទីក្រុងសឺរ៉ែណេវ ថ្ងៃទី១១-២៩ ខែកក្កដា ឆ្នាំ២០១១ (CCPR/C/GC/៣៤) កំណត់សម្គាល់ទូទៅលើកទី១៣។

[28] សាហាឌី ជីន "របៀបកម្មកម្រិតខ្ពស់របស់ ស៊ី ភី ជេ អាចចូលទៅប្រទេសវៀតណាម និងកម្ពុជា" គណៈកម្មាធិការដើម្បីការពារអ្នកសារព័ត៌មាន ឆ្នាំ១៩៩៦ អាចអានបាន ៖ http://cpj.org/reports/1996/10/viet.php និងអាចអានបាន ៖ http://www.cpj.org/attacks96/countries/asia/cambodiahrhs.html

[29] មាត្រា ១៩ អនុស្សរណៈស្តីពីច្បាប់របបសារព័ត៌មានរបស់កម្ពុជា ខែតុលា ឆ្នាំ២០០៤ ទំព័រទី៥ អាចអានបាន ៖ http://www.article19.org/data/files/pdfs/analysis/cambodia-press-law-oct-2004.pdf ។

មាត្រា ១២ បានចែងបន្ថែមទៀតថានឹងមិនរាប់បញ្ចូល "*ការផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ*" ។ ចាប់តាំងពីការអនុម័តច្បាប់ស្តីពីរបបសារព័ត៌មាន មានភាពមិនច្បាស់លាស់ជាបន្តបន្ទាប់ ថាតើគួរយកច្បាប់ណាមកប្រើដើម្បីកាត់ទោសអ្នកសារព័ត៌មានដែលរងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងបទល្មើសស្រដៀងគ្នានេះ។ **មាត្រា ២០** ចែងថា "*អំពើប្រព្រឹត្តដោយនិយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទដែលរំលោភច្បាប់ព្រហ្មទណ្ឌ ត្រូវទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ*" ។ "ច្បាប់ព្រហ្មទណ្ឌ" នេះ សំដៅលើក្រមព្រហ្មទណ្ឌអន្តរកាល និងដោយសារតែក្រមព្រហ្មទណ្ឌចូលជាធរមានក្នុងខែធ្នូ ឆ្នាំ២០១០។[30] ប៉ុន្តែ **មាត្រា ២០** បានចែងបន្តថា "*គ្មានជនណាម្នាក់ត្រូវចាប់ចង ឬជាប់ពន្ធនាគារ ដោយសារការបញ្ចេញមតិឡើយ*" ចំណែកឯ **មាត្រា ២១** បានចែងថា "*បទប្បញ្ញត្តទាំងឡាយណាដែលមានពីមុនមកហើយទាក់ទងនឹងសារព័ត៌មានត្រូវចាត់ទុកជានិរាករណ៍*" មាត្រាទាំងពីរបានបញ្ជាក់យ៉ាងច្បាស់ថា មាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌអន្តរកាល (ការបរិហារកេរ្តិ៍ និងការជេរប្រមាថ) ដែលបានសំដៅលើអ្នកនិពន្ធអត្ថបទ អ្នកបោះពុម្ព និងនិពន្ធនាយក នឹងលែងមានសុពលភាពអនុវត្តចំពោះវិស័យសារព័ត៌មាន ទោះបីជា ស្ថានភាពជាក់ស្តែង តុលាការប្រើនីតិវិធីច្បាប់ណាក៏ដោយ (សូមអានខាងក្រោម)។ ការលើកលែងក្នុង **មាត្រា ២០** រួមជាមួយ **មាត្រា ២១** ផ្ទុយពីផ្នែកទី១ នៃ **មាត្រា ២០** និង **មាត្រា១២** ដែលអនុញ្ញាតឲ្យមានការកាត់ទោសព្រហ្មទណ្ឌក្រោមច្បាប់ព្រហ្មទណ្ឌដែលកំពុងអនុវត្ត។ ម្យ៉ាងវិញទៀត ខណៈពេលដែល **មាត្រា ២០** បានចែងពីការការពារមួយចំនួន តែគ្មានការបញ្ជាក់ ឬការណែនាំណាមួយត្រូវបានយកមកបង្ហាញនោះទេថាមានកត្តាអ្វីខ្លះដែលចាត់ទុកថាជាការបញ្ចេញមតិ និងអ្វីខ្លះដែលអាចហៅថាជាការបរិហារកេរ្តិ៍ ឬជេរប្រមាថ នេះមានន័យថា ប្រសិទ្ធភាព និងភាពគួរឲ្យជឿជាក់នៃការលើកលែងនេះត្រូវរងការយោយីដោយសារតែការធ្វើសេចក្តីព្រាងបញ្ញត្តច្បាប់ដ៏ធូរលុង។

ក្នុងករណី *លោក ម៉ុង ឫទ្ធី និង កែវ សុជា (ខែមេសា ឆ្នាំ២០០២)* ដែលជានិពន្ធនាយកនៃសារព័ត៌មានមួយមានទំនាក់ទំនងនឹងគណបក្សប្រឆាំងត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ក្នុង មាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌអន្តរកាល ប៉ុន្តែបានជជែកការពារដោយជោគជ័យថាមាត្រានោះ បានចាត់ជានិរាករណ៍ដោយ **មាត្រា ១០** ក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន។ ទោះបីជាតុលាការទទួលយកការជជែកនេះ បញ្ហាមិនច្បាស់លាស់ដែលថាគួរតែយកច្បាប់ណាមកអនុវត្តក្នុងបណ្តឹងប្រឆាំងនឹងសារព័ត៌មាននៅតែមិនទាន់អាចដោះស្រាយបានព្រោះមានអ្នកសារព័ត៌មានជាច្រើនត្រូវបានកាត់ទោសពីបទបរិហារកេរ្តិ៍ដោយយោងតាមក្រមព្រហ្មទណ្ឌអន្តរកាល។ ត្រូវនៅចាំមើលបន្តទៀតថា តើការបញ្ជាក់ថ្មីៗក្នុងក្រមព្រហ្មទណ្ឌពាក់ព័ន្ធនឹងបទល្មើសដែលប្រព្រឹត្តដោយសារព័ត៌មាន នឹងមានន័យបែបណាចំពោះការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន។ ម្យ៉ាងវិញទៀត ក្នុងករណី *លោក ម៉ុង ឫទ្ធី* តុលាការរាជធានីភ្នំពេញ សម្រេចថា កែវ សុជា អាចនឹងប្រឈមមុខត្រឹមតែបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ (យោងតាម **មាត្រា ១០**) ប៉ុន្តែ អ្នកសារព័ត៌មាន និងនិពន្ធនាយកជាច្រើននៅតែបន្តទោសទោសប្បញ្ញត្តព្រហ្មទណ្ឌ មិនមែនទោសប្បញ្ញត្តរដ្ឋប្បវេណីនោះទេ ដែលការណ៍នេះផ្ទុយនឹងសេចក្តីសម្រេចរបស់តុលាការ។

ជាទ្រឹស្តីច្បាប់ស្តីពីរបបសារព័ត៌មាន មានចែងពីមាត្រាវិជ្ជមានមួយចំនួន ដែលគ្រប់គ្រាន់ក្នុងការការពារជាសារវ័ន្តដល់ជនគ្រប់រូបក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅមានមាត្រាមួយចំនួនដែលពុំច្បាស់លាស់ ដែលគំរាមកំហែងយ៉ាងខ្លាំង ដល់សេរីភាពបញ្ចេញមតិ ហើយមាត្រាទាំងនោះគួរតែត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម ដើម្បីញុំាងឲ្យច្បាប់នេះអាចការពារ និងលើកកម្ពស់របបសារព័ត៌មានសេរី ដូចបានសង្ឃឹម និងរំពឹងទុកកាលពីពាក់កណ្តាលទសវត្សន៍ទី ៩០។ ចំណុចសំខាន់បំផុតនោះ គឺថាមិនគួរមានឧបាស្រ័យ "ពីបទព្រហ្មទណ្ឌ" ក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន និងគួរតែមានការដោះស្រាយចំពោះបជីវាទកម្ម និងភាពមានន័យមិនច្បាស់លាស់ក្នុងពេលបច្ចុប្បន្ន ហើយតុលាការត្រូវតែផ្តល់ជាសេចក្តីណែនាំអំពីការអនុវត្តន៍ច្បាប់នេះ។ លើសពីនេះទៅទៀត ដោយយោងលើសេរីភាពបញ្ចេញមតិដែលទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិ ច្បាប់នេះមិនគួរមានបទបញ្ញត្តស្តីពីការដាក់ទណ្ឌកម្មព្រហ្មទណ្ឌចំពោះបទបរិហារកេរ្តិ៍ និងបទល្មើសពាក់ព័ន្ធដទៃ ដែលជាការរិះគន់ដែលត្រូវបានអនុវត្តដោយស្មើភាពក្នុងក្រមព្រហ្មទណ្ឌ។ ដោយសារតែមានការភ័យខ្លាចជាក់ស្តែង ជាពិសេសក្នុងបរិយាកាសសង្គមបច្ចុប្បន្ន ថារដ្ឋាភិបាលនឹងបន្តប្រើប្រាស់ច្បាប់ស្តីពីរបបសារព័ត៌មាន នៅក្នុង

[30] ដោយមិនគិតពីលទ្ធភាពដែលអាចនឹងត្រូវពិន័យជាប្រាក់ មានការសន្មត់ថាពាក្យ "ច្បាប់ព្រហ្មទណ្ឌ" មិនសំដៅលើ ច្បាប់ស្តីពីរបបសារព័ត៌មានផ្ទាល់ទេ មួយផ្នែកដោយសារតែបរិបទ និងមួយផ្នែកទៀតដោយសារតែហេតុផល និងគោលបំណងនៃច្បាប់ស្តីពីរបបសារព័ត៌មាន ដែលការពារអ្នកធ្វើការក្នុងវិស័យសារព័ត៌មានពីបណ្តឹងបទល្មើសបរិហារកេរ្តិ៍ ដោយហេតុនេះជួយលើកកម្ពស់ដល់សេរីភាពបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន។

យុទ្ធនាការរំលោភបំពាន និងគំរាមកំហែងមកលើប្រព័ន្ធផ្សព្វផ្សាយ បំបិទសំឡេងប្រឆាំង និងគាបសង្កត់លំហរប្រជាធិប្បតេយ្យនៅកម្ពុជា ដែលនេះជាការបំពានលើការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការគោរពសេរីភាពបញ្ចេញមតិ ដែលមានចែងក្នុងច្បាប់ជាតិ និងអន្តរជាតិ។

ច្បាប់ស្តីពីរបបសារព័ត៌មាន មិនមានបញ្ញត្តណាមួយចែងពីយុត្តាធិការក្រៅដែនសមត្ថកិច្ចនោះទេ ដូច្នេះអាចអនុវត្តបានចំពោះតែសារព័ត៌មានកម្ពុជាដែលបានបោះពុម្ពផ្សាយ ឬបានផ្សព្វផ្សាយ នៅក្នុងកម្ពុជាប៉ុណ្ណោះ។ ដូចបានចែងក្នុងសេចក្តីណែនាំក្នុងផ្នែកក្រមព្រហ្មទណ្ឌខាងលើ ក្រមព្រហ្មទណ្ឌ (មាត្រា ៣០៦, ៣០៨ និង ៤៩៧) ចែងពីបទល្មើសជាក់លាក់ រួមមានបទបរិហារកេរ្តិ៍ និងការជេរប្រមាថពេលដែលប្រព្រឹត្តដោយសារព័ត៌មាន និងការញុះញង់ដែលប្រព្រឹត្តតាមផ្លូវសារព័ត៌មាន គួរតែត្រូវបានផ្តន្ទាទោសក្រោមច្បាប់ស្តីពីរបបសារព័ត៌មាន ។

បទប្បញ្ញត្តចម្បងៗ ក្នុងច្បាប់ស្តីពីរបបសារព័ត៌មានដែលពាក់ព័ន្ធនឹងបទបរិហារកេរ្តិ៍ត្រូវបានរៀបរាប់ក្នុងតារាងខាងក្រោម ៖

ការផ្តន្ទាទោសព្រហ្មទណ្ឌអនុវត្តក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន			
បទល្មើស	**មាត្រា**	**ការផ្តន្ទាទោស**	**ការការពារ**
បទបរិហារកេរ្តិ៍ ការមួលបង្កាច់ ឬ បទជេរប្រមាថ ដែលប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គល	**មាត្រា ១០**	ពិន័យជាប្រាក់ពី ១លាន ទៅ ៥លានរៀល	**មាត្រា ២០** ក្នុងច្បាប់ស្តីពីរបបសារព័ត៌មានបានចែងថា ៖ *"អំពើប្រព្រឹត្តដោយនិយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទ ដែលរំលោភច្បាប់ច្បាប់ព្រហ្មទណ្ឌ ត្រូវទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏គ្មានជនណាម្នាក់ត្រូវចាប់ចង ឬជាប់ពន្ធនាគារ ដោយសារការបញ្ចេញមតិឡើយ"* ។ ខណៈពេលដែលការហាមឃាត់នេះបានផ្តល់ការការពារមួយចំនួន តែច្បាប់ស្តីពីរបបសារព័ត៌មានមិនបានបញ្ជាក់ ឬណែនាំឲ្យបានច្បាស់លាស់ថាមានកត្តាអ្វីខ្លះដែលចាត់ថាទុកជាការបញ្ចេញគំនិត ហើយមានកត្តាណាខ្លះដែលចាត់ទុកថាជាការជេរប្រមាថនោះទេ។ ដូច្នេះ ការការពារមួយនេះមិនអាចការពារបានពេញលេញនោះទេ តែនេះគឺជាការការពារតែមួយគត់ដែលមានចែងក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន។
ការញុះញង់ឲ្យប្រព្រឹត្តអំពើហិង្សា	**មាត្រា ១១**	ពិន័យជាប្រាក់ពី ១លាន ទៅ ៥លានរៀល	
ការបោះពុម្ពផ្សាយព័ត៌មានដែលប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថិរភាពនយោបាយ	**មាត្រា ១២**	និយោជក និពន្ធនាយក និងអ្នកនិពន្ធអត្ថបទនឹងត្រូវពិន័យជាប្រាក់ពី ៥លាន ទៅ ១៥លានរៀល ក្រសួងព័ត៌មាន និងក្រសួងមហាផ្ទៃអាចមានសិទ្ធិប្រមូលយកសារព័ត៌មានលេខចេញផ្សាយអត្ថបទល្មើស។ ក្រសួងព័ត៌មាន ក៏មានសិទ្ធិផ្អាកការផ្សាយក្នុងរយៈពេលមិនហួសពី ៣០ថ្ងៃ ហើយបញ្ជូនសំណុំរឿងទៅតុលាការ។	
បោះពុម្ពផ្សាយ ឬ ផ្សាយបន្តការមិនពិតដែលជាការជេរប្រមាថការមើលងាយដល់ស្ថាប័នជាតិ	**មាត្រា ១៣**	ពិន័យជាប្រាក់ពី ២លាន ទៅ ១០លានរៀល	
បោះពុម្ពផ្សាយនូវអ្វីដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិ	**មាត្រា១៤**	ពិន័យជាប្រាក់ពី ១លាន ទៅ ៥លានរៀល	
ការផ្តន្ទាទោសផ្សេងៗដែលអនុវត្តក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន			
បទបរិហារកេរ្តិ៍ និងការជេរប្រមាថខុសពីលក្ខណៈពិតផ្សាយក្នុងសារព័ត៌មានដែលប៉ះពាល់ដល់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់បុគ្គល	**មាត្រា ១០**	• ចុះផ្សាយកែសម្រួល • សងដំងឺចិត្ត • ចុះផ្សាយនូវការកែសម្រួលផង និងបង់ប្រាក់សងដំងឺចិត្តផង ឬ • ចុះផ្សាយសាលក្រមរបស់តុលាការក្នុងសារព័ត៌មាន និងឲ្យជនជាប់ចោទទទួលបន្ទុកចេញសោហ៊ុយ (ការ	សូមអានការការពារខាងលើ (ការការពារចំពោះបទប្បញ្ញត្តព្រហ្មទណ្ឌ)

		ចំណាយកម្រិតត្រឹម ១លានរៀល យ៉ាងច្រើនបំផុត)	
ការញុះញង់ឲ្យប្រព្រឹត្តអំពើហិង្សា	**មាត្រា ១១**	ជនរងគ្រោះមានសិទ្ធិដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី គ្មានការផ្តន្ទាទោសជាក់លាក់ត្រូវបានរៀបរាប់នោះទេ។ **កំណត់សម្គាល់** ៖ អត្ថបទណាដែលត្រូវបានអះអាងថាបានញុះញង់ឲ្យបុគ្គលប្រព្រឹត្តអំពើហិង្សាមិនអាចត្រូវបានយកមកសំអាងក្នុងការចោទប្រកាន់បានឡើយ ប្រសិនបើអត្ថបទនោះមានចំណាស់លើស ពី៣ខែ	

បទបរិហារកេរ្តិ៍ត្រូវបានប្រើជាឧបករណ៍ច្បាប់ដោយរដ្ឋាភិបាល និងតុលាការ

ការបន្តប្រើប្រាស់ បណ្តឹងបទបរិហារកេរ្តិ៍ និងបណ្តឹងបទល្មើសស្រដៀងគ្នា បានបង្ហាញពីនិន្នាការនៃការប្រើប្រាស់តុលាការកម្ពុជាជាឧបករណ៍គាបសង្កត់ ដើម្បីលុបបំបាត់ការរិះគន់ចំពោះរដ្ឋាភិបាល និងគោលនយោបាយរបស់រដ្ឋាភិបាល។ វិធីសាស្ត្រនេះ មានភស្តុតាងបញ្ជាក់យោងតាមករណីសិក្សាជាបន្តបន្ទាប់ មួយចំនួនខាងក្រោម តែករណីទាំងនេះមិនមែនជាករណីទាំងអស់ដែលកើតមាននោះទេ ៖

1. **លោកស្រី មូរ សុខហួរ** ៖ សមាជិកសភានៃគណបក្ស សម រង្ស៊ី ជាគណបក្សប្រឆាំងត្រូវផ្តន្ទាទោសពីបទបរិហារកេរ្តិ៍ប្តឹងដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បន្ទាប់ពីរូបលោកស្រីត្រូវបានដកអភ័យឯកសិទ្ធិជាសមាជិកសភាទាំងមានភាពចម្រូងចម្រាស់។ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ លោកស្រី មូរ សុខហួរ បានដាក់ពាក្យបណ្តឹងប្រឆាំងនឹង លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ក្នុងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌអន្តរកាល ឆ្លើយតបចំពោះសុន្ទរកថារបស់ លោក ហ៊ុន សែន ដែលបាននិយាយសំដៅលើសមាជិកសភាស្ត្រីម្នាក់នៃគណបក្សប្រឆាំងដោយមិនបញ្ចេញឈ្មោះ តែអាចកំណត់អត្តសញ្ញាណបានដោយងាយ ថាជា លោកស្រី មូរ សុខហួរ យោងតាមបរិបទនៃពាក្យថា *"ជើងខ្លាំង"* ពាក្យប្រមាថដែលសំដៅថាមនុស្សម្នាក់ជាជនខិលខូច និង/ឬ ជាពិសេសពេលសំដៅលើមនុស្សស្រី មានន័យថា ស្រីអ្នកលេង។[31] មាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌអន្តរកាលបានចែងថា *"ការចោទប្រកាន់ ឬទម្លាក់កំហុសដោយគ្មានភស្តុតាងគឺនឹងត្រូវមានទោស ទោះបីជាសំដៅទៅលើជនណាមួយដោយមិនបង្ហាញឈ្មោះ ប៉ុន្តែកិនភាគបានបញ្ជាក់ច្បាស់តាមន័យក្នុងសម្តី តាមសម្រែក តាមការគំរាមកំហែង តាមការសរសេរ ឬតាមការបោះពុម្ព តាមផ្ទាំងបដារ ឬប័ណ្ណប្រកាស តាមការផ្សាយសោតទស្សន៍ដែលជាប់ចោទ"* ។[32]

បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បដិសេធមិនព្រមដកសម្តី លោកស្រី មូរ សុខហួរ បានដាក់ពាក្យបណ្តឹងដោយទាមទារ សំណង ៥០០រៀល សម្រាប់ជានិមិត្តរូបនៃសំណង។ លោកនាយករដ្ឋមន្ត្រី បានឆ្លើយតបដោយដាក់ពាក្យបណ្តឹងតបដោយអះអាងថា លោកស្រី មូរ សុខហួរ បានបរិហារកេរ្តិ៍លោក តាមរយៈសម្តី ដែលថាពាក្យសម្តីរបស់លោកនាយករដ្ឋមន្ត្រីប៉ះពាល់ដល់ស្ត្រីខ្មែរទាំងអស់។ មានការគំរាមដាក់ពាក្យបណ្តឹងពីបទបរិហារកេរ្តិ៍ប្រឆាំងនឹងមេធាវីរបស់ លោកស្រី មូរ សុខហួរ បង្ខំឲ្យរូបលោកឈប់ទទួលការពាររឿងក្តីនេះ ដូច្នេះបានដកហូតសិទ្ធិក្នុងការមានតំណាងស្របច្បាប់របស់លោកស្រី។ កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ក្នុងតុលាការរាជធានីភ្នំពេញ បានលើកបណ្តឹងប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រី ដោយនិយាយថាបណ្តឹងនេះគ្មានហេតុផល។ ព្រះរាជអាជ្ញា លោក ហ៊ីង ប៊ុនជា បានពន្យល់ក្នុងសុន្ទរកថាចំនួនបីទំព័រថា ដោយសារតែពាក្យសម្តីរបស់ លោកនាយករដ្ឋមន្ត្រី មិនបាននិយាយចំឈ្មោះ លោកស្រី មូរ សុខហួរ ហើយលោកនាយករដ្ឋមន្ត្រីក៏គ្មានបំណងដេរប្រមាថបុគ្គលណា

[31] វិទ្យុអូស្ត្រាលី "សមាជិកសភាគណបក្សប្រឆាំងប្តឹង លោក ហ៊ុន សែន ពីបទបរិហារកេរ្តិ៍" កិច្ចសម្ភាសន៍រវាង លោក រ៉ូប៊ឺត ខាមីខែល និង លោកស្រី មូរ សុខហួរ ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៩ អាចអានបាន ៖ http://www.radioaustralia.net.au/connectasia/stories/200904/s2551808.htm ។

[32] ការសង្កត់ធ្ងន់ត្រូវបានបន្ថែម។

ដោយពាក្យសម្តីរបស់លោកនោះទេ ដូច្នេះ ធ្វើឲ្យពាក្យបណ្តឹងគ្មានសុពលភាព។[33] ហេតុផលបែបនេះគឺជាការអនុវត្តខុសនឹងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌអន្តរកាល ដូចដែលបានរៀបរាប់ពីខាងលើ។

តុលាការសម្រេចបន្តដំណើរការពាក្យបណ្តឹងតបរបស់លោកនាយករដ្ឋមន្ត្រី។ សវនាការរបស់លោកស្រី មូរ សុខហួរ ទាំងផ្ទាល់ (និងដោយប្រយោល) ពាក់ព័ន្ធនឹងចៅក្រមមួយចំនួនដែលអាចមានឥទ្ធិពលមកលើដំណើរការតុលាការ និងមានទំនាក់ទំនងជាក់លាក់ជាមួយលោកនាយករដ្ឋមន្ត្រី និងគណបក្សរបស់លោកគឺគណបក្សប្រជាជនកម្ពុជា។ ទីបំផុត លោកស្រី មូរ សុខហួរ ត្រូវបានរកឃើញថាមានទោសពីបទបរិហារកេរ្តិ៍ និងត្រូវបានពិន័យជាប្រាក់ចំនួន ១៦.៥ លានរៀល ជាការពិន័យ និងសងជំងឺចិត្ត។ លោកស្រីបដិសេធមិនព្រមបង់ប្រាក់ ដោយនិយាយថាលោកស្រីសុខចិត្តជាប់ពន្ធនាគារជំនួសវិញ។ លោកស្រីមិនបានជាប់ពន្ធនាគារនោះទេ ដោយសារតែប្រាក់ខែរបស់លោកស្រីជាសមាជិកសភាត្រូវបានកាត់យកមកទូទាត់ជាមួយនឹងប្រាក់ពិន័យ។ តាមរយៈការពិនិត្យមើលឡើងវិញរបស់ ម.ស.ម.ក លើក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌអន្តរកាល ជំហានមួយនេះ គឺដើម្បីចៀសវាងមិនឲ្យមានការប្តេជ្ញាទោសពីសហគមន៍ជាតិ និងអន្តរជាតិ ប៉ុន្តែគឺគ្មានគោលការណ៍គតិយុត្តនោះទេ។ ទោះបីជាយ៉ាងការដាក់ទណ្ឌកម្មនេះមិនមែនជាសេចក្តីសម្រេចរបស់តុលាការនោះទេ។[34]

2. **លោក ខេវិន ដូល និង នៅ រ៉ណ្ណារិទ្ធ** ៖ និពន្ធនាយកនៃ សារព័ត៌មាន ឌឹ ខេមបូឌា ដេលី និងអ្នកសារព័ត៌មានមួយរូប ត្រូវបានរកឃើញថាមានទោសពីបទបរិហារកេរ្តិ៍ ក្នុងឆ្នាំ២០០៩ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ១,០០០ដុល្លារ ។ ពួកគេត្រូវបានផ្តន្ទាទោសពីបទបរិហារកេរ្តិ៍ យោងតាមមាត្រា ១០ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ដោយសារតែការបោះពុម្ពផ្សាយអត្ថបទដកស្រង់ការរិះគន់របស់ លោក ហូរ វ៉ាន់ សមាជិកសភានៃគណបក្ស សម រង្ស៊ី ចំពោះមន្ត្រីយោធាទាក់ទិននឹងសញ្ញាប័ត្រដែលផ្តល់ជូនដល់យោធាកម្ពុជាពីសាលាយោធាវៀតណាម។[35] លោក ហូរ វ៉ាន់ បានអះអាងថាលោកត្រូវបាន សារព័ត៌មាន ឌឹ ខេមបូឌា ដេលី ដកស្រង់សម្តីលោកខុស ហើយសារព័ត៌មាននេះក៏បានបោះផ្សាយនូវអត្ថបទកែតម្រូវរួចរាល់ផងដែរ។ លោក ហូរ វ៉ាន់ មិនត្រូវបានរកឃើញថាមានទោសនោះទេ ប៉ុន្តែអ្នកសារព័ត៌មាននោះត្រូវបានផ្តន្ទាទោស ទោះបីជាមានអត្ថបទកែតម្រូវក៏ដោយ។

3. **លោក សម រង្ស៊ី** ៖ ប្រធានគណបក្ស សម រង្ស៊ី និងជាប្រធានគណបក្សដែលទើបនឹងរួមបញ្ចូលថ្មី គណបក្ស សង្គ្រោះជាតិ ត្រូវបានកាត់ទោស កាលពី ថ្ងៃទី២៧ ខែមករា ឆ្នាំ ២០១០ ពីបទញុះញង់ឲ្យមានការរើឯងអើង និងកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ ពីបទផ្តល់ព័ត៌មានមិនពិត (ក្នុងចំណោមការចោទប្រកាន់ដទៃទៀត) បទល្មើសទាំងពីរនេះមានក្នុងក្រមព្រហ្មទណ្ឌអន្តរកាល។ ព្រឹត្តិការណ៍ដែលនៅពីក្រោយការចោទប្រកាន់នេះ គឺលោក សម រង្ស៊ី បានដកបង្គោលព្រំដែន កាលពី ថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០០៩ ដើម្បីប្រឆាំងនឹងការឈ្លានពានរបស់អាជ្ញាធរវៀតណាម។ លោក សម រង្ស៊ី ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារយៈពេលសរុប ១២ឆ្នាំ និងមានការពិន័យជាប្រាក់ចំនួនរាប់លានរៀល និងការផ្តល់ "សំណងជូនដល់រដ្ឋ" ទោះបីជា រូបលោកកំពុងភៀសខ្លួននៅក្នុងប្រទេសបារាំងក៏ដោយ។[36]

---

[33] ម.ស.ម.ក "វិភាគផ្នែកច្បាប់ ៖ ករណីនៃព្រះរាជាណាចក្រកម្ពុជា ជាមួយ លោកស្រី មូរ សុខហួរ" ខែឧសភា ឆ្នាំ២០១០ អាចអានបាន ៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=11&id=5 ។

[34] មាស សុខដា "ការពិន័យរបស់ សុខហួរ ត្រូវបានកាត់ចេញពីប្រាក់បៀវត្ស" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១០ អាចអានបាន ៖ http://www.phnompenhpost.com/index.php/2010081241186/National-news/sochua-fine-to-be-docked-from-pay.html ។

[35] មាស សុខដា និង ចេមស៍ អូ ធូល "តុលាការរាជធានីគួរតែដោះលែងបុគ្គលិកសារព័ត៌មានដេលី ៖ ហូរ វ៉ាន់" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៩ អាចអានបាន ៖ http://khmernz.blogspot.com/2009/09/city-court-should-spare-daily-staffers.html ។

[36] សម្រាប់ព័ត៌មានបន្ថែម សូមអាន "ការវិភាគលើមូលដ្ឋានច្បាប់សម្រាប់ការកាត់ទោស និងភាពយុត្តិធម៌នៃដំណើរការតុលាការនៃបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹង សម រង្ស៊ី" របស់ ម.ស.ម.ក ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ អាចអានបាន ៖ http://www.cchrcambodia.org/index.php?url=media/media.php&p=analysis_detail.php&anid=1&id=5 ។

4. **លោក សេង គុណ្ណាកា** ៖ បុគ្គលិកនៃកម្មវិធីស្បៀងអាហារអង្គការសហប្រជាជាតិ ក្នុងរាជធានីភ្នំពេញ ត្រូវបាននគរបាលខណ្ឌឫស្សីកែវចាប់ខ្លួន កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ និងចោទប្រកាន់ពីបទចែកចាយខិត្តប័ណ្ណដែលបានមកពីគេហទំព័រ ខេ អាយ មីឌៀ ដែលជាគេហទំព័ររិះគន់រដ្ឋាភិបាល ដល់សហការីរបស់លោក។ រយៈពេល ២ថ្ងៃក្រោយ នៅព្រឹកថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១០ ត្រូវនឹងថ្ងៃអាទិត្យដែលជាថ្ងៃឈប់សម្រាករបស់តុលាការ លោក សេង គុណ្ណាការ ត្រូវបានរកឃើញថាមានទោសដោយតុលាការរាជធានីភ្នំពេញ ពីបទញុះញង់ឲ្យប្រព្រឹត្តបទល្មើសក្រោមមាត្រា ៤៩៥ ក្នុងក្រមព្រហ្មទណ្ឌ។ គាត់ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារយៈពេល ៦ខែ និងពិន័យជាប្រាក់ចំនួន ១លានរៀល (ប្រហែលជា ១៨៨អឺរ៉ូ និង២៤៦ដុល្លារ)។[37] ការកាត់ទោសរបស់ លោក សេង គុណ្ណាការ បានបង្ហាញថារដ្ឋាភិបាលត្រៀមខ្លួនជាស្រេច ក្នុងការផ្តន្ទាទោសចំពោះបុគ្គលណាដែលប្រើប្រាស់អ៊ីនធើណែត ចែករំលែកពីគំនិតប្រឆាំងនឹងរដ្ឋាភិបាល។ ដោយសារមានការផ្តន្ទាទោសដល់បុគ្គលដែលបានបញ្ចេញមតិតាមរយៈទំព័រសារព័ត៌មាន ការណ៍នេះត្រូវបានសន្មត់ថាការផ្តន្ទាទោសមានបំណងជាការដាក់ទារុណកម្ម ជាជាងការបំភ័យ ដែលគឺជាសារដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ថា ប្រសិនបើពួកគាត់ប្រើប្រាស់អ៊ីនធើណែតដើម្បីបញ្ចេញគំនិតដែលមិនស្របនឹងគំនិតរបស់រដ្ឋាភិបាល ពួកគាត់អាចប្រឈមនឹងការផ្តន្ទាទោស។[38] អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានថ្កោលទោសចំពោះការសេចក្តីសម្រេចទោសក្នុងករណីនេះ ថាសេរីភាពបញ្ចេញមតិនៅកម្ពុជាកំពុងតែដើរថយក្រោយ។[39]

5. **លោក សោម ចាន់គា** ៖ កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១ អ្នកសម្របសម្រួលថ្នាក់ខេត្តនៃសមាគមការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍នៅកម្ពុជា លោក សោម ចាន់គា ត្រូវបានរកឃើញថាមានទោសពីបទបរិហារកេរ្តិ៍ តាមមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ដោយសារតែលោកបានបញ្ចេញមតិលើវិទ្យុអាស៊ីសេរីក្នុងឆ្នាំ ២០០៩ ពាក់ព័ន្ធនឹងក្រុមហ៊ុន ខេ ឌី ស៊ី អន្តរជាតិ ដែលគ្រប់គ្រងដោយភរិយារបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានការពាក់ព័ន្ធនឹងដម្លៅដីធ្លីរ៉ាំរ៉ៃមួយនៅក្នុងខេត្តកំពង់ឆ្នាំង។ លោក សោម ចាន់គា ត្រូវពិន័យជាប្រាក់ចំនួន ១លានរៀល និងប្រាក់ចំនួន ៣លានរៀលសម្រាប់សងដំងឺចិត្តជូនទៅក្រុមហ៊ុន។[40] ករណីនេះបានបង្ហាញពីហានិភ័យដែលអាចនឹងកើតមាន ដោយសារការអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិ ជាពិសេសពេលដែលរិះគន់រដ្ឋាភិបាល ឬសមាជិកក្រុមអភិជន។ មួយវិញទៀត ក្រមព្រហ្មទណ្ឌ ឬការគំរាមកំហែងដាក់ទណ្ឌកម្ម បានបង្ហាញថានេះ គឺជាមធ្យោបាយចម្បងសម្រាប់បង្ក្រាបមកលើសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋកម្ពុជា។

6. **លោក ហ៊ុន ពិសិដ្ឋ** ៖ ក្នុងខែមិនា ឆ្នាំ២០១១ អ្នករត់ម៉ូតូឌុបម្នាក់ ត្រូវបានរកឃើញថាមានទោសពីបទញុះញង់ឲ្យមានការរើសអើងដោយតុលាការរាជធានីភ្នំពេញ ព្រោះបានចែកចាយខិត្តប័ណ្ណប្រឆាំងនឹងរដ្ឋាភិបាល និងត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ១ឆ្នាំកន្លះ និងពិន័យជាប្រាក់ចំនួន ៧៥០ដុល្លារ។ លោក ហ៊ុន ពិសិដ្ឋ បានអះអាងថា គាត់បានដឹកស្រីម្នាក់ដែលចែកចាយខិត្តប័ណ្ណបានមកពីសារព័ត៌មាន ឌឹ ខេមបូឌា ដេលី "*ការប្រៀបធៀបដែលសមប្រកបរវាងអ្នកដឹកនាំរដ្ឋាភិបាល និងពូជសាសន៍មកពីប្រទេសមួយទៀត*" ដែលគាត់មិនបានដឹងខ្លួនទេ។ លោក អ៊ូ វីរៈ ប្រធាន ម.ស.ម.ក បានមានប្រសាសន៍ចំពោះការផ្តន្ទាទោសនេះថា ៖ "*ការដាក់ពន្ធនាគារ លោក ហ៊ុន ពិសិដ្ឋ គឺហាក់ដូចជាបង្ហាញឲ្យឃើញថារដ្ឋាភិបាលមានបំណងកំណត់យុត្តិសាស្ត្រថ្មីមួយ ដោយ*

---

[37] មូលនិធិអន្តរជាតិដើម្បីសិទ្ធិមនុស្ស "កម្ពុជា៖ ការយោយឺមកលើសេរីភាពបញ្ចេញមតិបន្តដោយមានការផ្តន្ទាទោសមកលើបុគ្គលិក អង្គការសហប្រជាជាតិ" ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០ អាចអានបាន៖ http://www.fidh.org/Cambodia-Assault-on-freedom-of-expression ។

[38] អង្គការឃ្លាំមើលសិទ្ធិមនុស្ស "កម្ពុជា៖ ក្រមព្រហ្មទណ្ឌថ្មីកាត់បន្ថយការនិយាយស្តីដោយសេរី" ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០ អាចអានបាន ៖ http://www.hrw.org/en/news/2010/12/22/cambodia-new-penal-code-undercuts-free-speech ។

[39] កន្លែងដដែល។

[40] មជ្ឈមណ្ឌលកម្ពុជា (ម.ស.ម.ក) និង មាត្រា១៩ "កម្ពុជា ៖ ការផ្តន្ទាទោសមកលើ លោក សោម ចាន់គា គឺជាការវាយប្រហារមកលើសេរីភាពបញ្ចេញមតិ" សេចក្តីថ្លែងការណ៍ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១ អាចអានបាន ៖ http://www.article19.org/data/files/pdfs/press/cambodia-conviction-of-sam-chankea-is-an-attack-on-freedom-of-expression.pdf ។

កំណត់ជាកាតព្វកិច្ចដល់ប្រជាពលរដ្ឋទាំងអស់ មិនមែនត្រឹមតែមិនគួរនិយាយពីអ្វីដែលពួកគាត់គិតនោះទេ តែថែមទាំងមិនឲ្យពួកគេមានទំនាក់ទំនង ជាមួយនឹងបុគ្គលដែលហ៊ានបញ្ចេញគំនិត ទោះបីដោយដឹងខ្លួន ឬមិនដឹងខ្លួនក៏ដោយ" ។[41]

7. **ស្ត្រីបឹងកក់ចំនួន១៣នាក់** ៖ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ សកម្មជនស្ត្រីចំនួន១៣នាក់ ជាតំណាងសហគមន៍បឹងកក់ ដែលរងការប៉ះពាល់ពីការដេញចេញដោយបង្ខំត្រូវបានចាប់ខ្លួន កាត់ទោស និងដាក់ពន្ធនាគារក្នុងរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ។ ស្ត្រីទាំង១៣នាក់ រួមមាន ចាន់ ណារី, ឆេង លាភ, ហេង មុំ, គង់ ចន្ថា, ង៉ែត ឃុន, ងួន គីមឡាង, ជាន់ ឈុនរ៉េត, ពៅ សុភា, សុង ស្រីលាភ, សួង សម័យ, ទេព វណ្ណី, ថូ ដារី, និងតុល ស្រីពៅ ត្រូវបានផ្តន្ទាទោសដោយមាត្រា៥០៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ (ស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ) និងមាត្រា៣៨ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ (ការកាន់កាប់ដីធ្លីដោយមិនស្របច្បាប់)។ ពួកគេទាំង ១៣នាក់ ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួនពីរឆ្នាំកន្លះ ដែលស្ត្រីចំនួន ៥នាក់ត្រូវបានព្យួរទោស ហើយទោសរបស់លោកយាយអាយុ ៧២ឆ្នាំ ចំនួន១ឆ្នាំកន្លះ ត្រូវបានព្យួរ។ បទចោទប្រកាន់នេះពាក់ព័ន្ធនឹងការប្រឆាំងតវ៉ាដោយសន្តិវិធីនៅតំបន់បឹងកក់ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២។[42] កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ សាលាឧទ្ធរណ៍បានកាត់បន្ថយទោសរបស់ស្ត្រីទាំង១៣នាក់ ឲ្យនៅត្រឹម ១ខែនិងបីថ្ងៃ ដែលជាពេលវេលាដែលពួកគេត្រូវបានឃុំខ្លួន ហើយពួកគេត្រូវបានដោះលែងក្រោយមកទៀតក្នុងថ្ងៃដដែលនេះ។ ប៉ុន្តែ ខណៈពេលដែលស្ត្រីទាំងអស់នេះត្រូវបានអនុញ្ញាតឲ្យត្រលប់ទៅផ្ទះ ភាពអយុត្តិធម៌នៅតែមានព្រោះថាការសម្រេចទោសរបស់ស្ត្រីទាំងអស់នេះនៅដដែល។[43]

8. **ព្រះតេជគុណ លួន សុវ៉ាត** ៖ ជាព្រះសង្ឃ និងអ្នកការពារសិទ្ធិមនុស្ស ព្រះតេជគុណ លួន សុវ៉ាត ត្រូវបានឃុំខ្លួនប្រហែលជា ១០ម៉ោង ដោយអាជ្ញាធរកាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២។ ព្រះតេជគុណ លួន សុវ៉ាត ត្រូវបានចាប់ខ្លួន និងបង្ខំឲ្យចូលឡាន ដែលក្រោយមកត្រូវបាននាំខ្លួនចេញពីសាលាដំបូងរាជធានីភ្នំពេញភ្លាមៗ បន្ទាប់ពីព្រះតេជគុណ បានថតរូបប្រជាពលរដ្ឋដែលប្រឆាំងតវ៉ាចំពោះការចាប់ខ្លួនរបស់ស្ត្រីនៅបឹងកក់ទាំង ១៣រូបនោះ។[44] ក្រោយមក ព្រះតេជគុណ លួន សុវ៉ាត បាននិយាយថាព្រះតេជគុណត្រូវបានគេបង្ខំឲ្យស្របតាមការបង្ខិតបង្ខំ និងផ្តិតមេដៃនៅលើកិច្ចសន្យានៅចំពោះមុខមន្ត្រីសង្ឃ។ ចៅក្រម ឌុច គឹមសន បានសំណូមពរឲ្យ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លោក អង្គ វង្សវឌ្ឍនា រៀបចំឲ្យមានការស៊ើបអង្កេតចំពោះការចោទប្រកាន់ពីបទញុះញង់។ ព្រះតេជគុណ ត្រូវបានគំរាមថានឹងចាប់ផ្សឹកប្រសិនបើព្រះតេជគុណនៅតែចូលរួមការប្រឆាំងតវ៉ានាពេលអនាគត។ មួយឆ្នាំមុន សម្តេចព្រះសង្ឃរាជ ន ន្ទ ង៉ែត បានហាមឃាត់ ព្រះតេជគុណ លួន សុវ៉ាត មិនឲ្យចូលទៅក្នុងវត្តទាំងអស់នៅទីក្រុងភ្នំពេញ ដោយសារតែសកម្មភាពសកម្មនិយមរបស់ព្រះតេជគុណក្នុងរឿងដីធ្លី។[45]

---

[41] មជ្ឈមណ្ឌលកម្ពុជា (ម.ស.ម.ក) "ការផ្តន្ទាទោសមកលើអ្នករត់ម៉ូតូឌុបបង្ហាញពីភាពភ័យខ្លាចរបស់រដ្ឋាភិបាល" ចេញផ្សាយថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១១ អាចអានបាន ៖
http://www.cchrcambodia.org/index_old.php?url=project_page/project_page.php&p=press_detail.php&prid=153&id=3 ។

[42] ម.ស.ម.ក "ការវិភាគផ្នែកច្បាប់អំពីការកែប្រែបទចោទ និងការផ្តន្ទាទោសមកលើស្ត្រីអ្នកតំណាងបឹងកក់ទាំង ១៣រូប កាលពីថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០១២" ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ អាចអានបាន ៖
http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=19&id=5 ។

[43] សេចក្តីថ្លែងការណ៍ ម.ស.ម.ក "ការដោះលែងសកម្មជនបឹងកក់លុបគ្របដណ្តប់លើបារាជ័យក្នុងការសម្រេចបាននូវយុត្តិធម៌ និងបន្តឲ្យមានអំពើហិង្សាប្រឆាំងនឹងអ្នកតវ៉ាដោយសន្តិវិធី" ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ អាចអានបាន ៖
http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=260&id=5 ។

[44] ឃុត សុភ័ក្ត្រ ចរិយា "ព្រះតេជគុណ លួន សុវ៉ាតដែលជាសកម្មជន ត្រូវបានឃុំខ្លួន" សារព័ត៌មាន ឌឺ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ អាចអានបាន ៖ http://www.phnompenhpost.com/index.php/2012052456374/National-news/activist-monk-loun-savath-detained.html ។

[45] ម៉ៃ ទិត្យថារ៉ា "ព្រះតេជគុណ លួន សុវ៉ាត មានសង្ឃដីកាថា ជាការព្រមព្រៀងដោយបង្ខំ" សារព័ត៌មាន ឌឺ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២ អាចអានបាន ៖ http://www.phnompenhpost.com/index.php/2012052856419/National-news/agreement-forced-monk-says.html ។

9. **ម៉ម សូណង់ដូ** ៖ កាលពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១២ លោក ម៉ម សូណង់ដូ នាយកនៃស្ថានីយវិទ្យុសំបុកឃ្មុំ និងជាប្រធាននៃសមាគមអ្នកប្រជាធិបតេយ្យ ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួន ២០ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០លានរៀល ពីបទផ្តើមគំនិតឲ្យមានចលនាអបគមន៍ក្នុងខេត្តក្រចេះ កាលពីខែឧសភា ឆ្នាំ២០១២ និងញុះញង់ឲ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងអ្នករាជការសាធារណៈ យោងតាម មាត្រា ២៨ ៤៥៦, ៤៥៧, ៤៦៤, ៥០៤ និង ៦០៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា។[46] លោកត្រូវបានចាប់ខ្លួននៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២។ នេះមិនមែនជាលើកទីមួយទេ ដែលលោក ម៉ម សូណង់ដូ ត្រូវបានឃុំខ្លួនក្នុងករណីដែលពាក់ព័ន្ធនឹងនយោបាយនេះ ៖ ក្នុងឆ្នាំ២០០៣ លោកត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួនពីរសប្តាហ៍បន្ទាប់ពីបានផ្សាយនូវការហៅទូរសព្ទចូលមកកាន់ស្ថានីយវិទ្យុសំបុកឃ្មុំ ដែលរដ្ឋាភិបាលពិចារណាថាជាការញុះញង់ឲ្យប្រព្រឹត្តបទល្មើស និងឲ្យមានការរើសអើង យោងតាមច្បាប់ក្រមព្រហ្មទណ្ឌអន្តរកាល។ ក្នុងឆ្នាំ២០០៥ លោក ម៉ម សូណង់ដូ ត្រូវជាប់ពន្ធនាគារចំនួន ៣ខែ ពីបទបរិហារកេរ្តិ៍ និងញុះញង់ យោងតាមច្បាប់ក្រមព្រហ្មទណ្ឌអន្តរកាល បន្ទាប់ពីបានធ្វើបទសម្ភាសន៍ជាមួយនឹងអ្នកជំនាញម្នាក់ គឺ លោក ស៊ាន ប៉េងសៃ ដែលរស់នៅប្រទេសបារាំង ដែលបានរិះគន់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចំពោះការពាក់ព័ន្ធនឹងសម្បទានព្រំដែនឲ្យទៅប្រទេសវៀតណាម។[47]

ការកាត់ទោស លោក ម៉ម សូណង់ដូ មានការជាប់ពាក់ព័ន្ធនឹងរបាយការណ៍ដែលបានផ្សាយនៅលើស្ថានីយវិទ្យុសំបុកឃ្មុំ ស្តីពីការដាក់ពាក្យបណ្តឹងទៅការិយាល័យព្រះរាជអាជ្ញានៃតុលាការយុត្តិធម៌អន្តរជាតិ ដោយប្រជានចលនាអំណាចប្រជាពលរដ្ឋខ្មែរ លោក សួន សេរីរដ្ឋា ដោយចោទប្រកាន់ថារដ្ឋាភិបាលមានការពាក់ព័ន្ធនឹងបទល្មើសប្រឆាំងមនុស្សជាតិ ដែលជាលទ្ធផលនៃការបណ្តេញចេញពីដីដោយបង្ខំ។[48] ប៉ុន្តែ បន្ទាប់ពីមានការស្លាប់របស់ក្មេងស្រីអាយុ១៤ឆ្នាំ ក្នុងអំឡុងពេលការប្រឆាំងតវ៉ានៅភូមិប្រម៉ា ខេត្តក្រចេះ ប្រឆាំងនឹងការបណ្តេញចេញប្រជាពលរដ្ឋប្រហែល ១០០០គ្រួសារ មន្ត្រីនគរបាលបានចាប់ឃាត់ខ្លួនបុគ្គលមួយចំនួន ដែលពួកគេនិយាយថាក្រុមបង្កើតតំបន់អបគមន៍ទាមទារឯករាជ្យពីប្រទេសកម្ពុជា។ រដ្ឋាភិបាលកម្ពុជា អះអាងថា ការបង្កើតតំបន់អបគមន៍នេះត្រូវបានរៀបចំផែនការជាមួយ សមាគមអ្នកប្រជាធិបតេយ្យ ដឹកនាំដោយ លោក ម៉ម សូណង់ដូ។ កស្តុតាងចំពោះការអះអាងទាំងនេះ មិនត្រូវបានបង្ហាញនៅក្នុងតុលាការនោះទេ។ ការពាក់ព័ន្ធរបស់ លោក ម៉ម សូណង់ដូ តែមួយគត់គឺការផ្សាយពីព្រឹត្តិការណ៍បណ្តេញចេញនោះនៅលើស្ថានីយវិទ្យុសំបុកឃ្មុំ។[49] សំណុំរឿងរបស់លោក បង្ហាញជាសង្ខេបនូវកង្វះខាតការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់រដ្ឋាភិបាល លំហរសេរីភាពបញ្ចេញមតិដែលកាន់តែចង្អៀត និងការប្រើប្រាស់ប្រព័ន្ធតុលាការដោយខុសដើម្បីបំបិទមតិប្រឆាំង។ លោក ម៉ម សូណង់ដូ បានដាក់ពាក្យប្តឹងទៅកាន់សាលាឧទ្ធរណ៍រួចរាល់ហើយ តែមិនទាន់បានកំណត់ថ្ងៃសម្រាប់សវនាការនៅឡើយទេ។

10. **លោក ចាន់ សុវ៉ែត** ៖ កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១២ តុលាការដំបូងរាជធានីភ្នំពេញបានកោះហៅលោក ចាន់សុវ៉ែត មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់ នៃសមាគមអាដហុកការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) ដើម្បីឲ្យបង្ហាញខ្លួននៅមុខតុលាការនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១២ ដើម្បីឆ្លើយតបចំពោះការចោទប្រកាន់ពីបទ "ផ្តល់ ជំនួយដល់ជនល្មើស" នៃ

---

[46] កំណត់ត្រាសង្ខេប ម.ស.ម.ក "ករណីអ្នកការពារសិទ្ធិមនុស្ស ម៉ម សូណង់ដូ" ខែសីហា ឆ្នាំ២០១២ អាចអានបាន ៖ http://www.ifex.org/cambodia/2012/08/03/cambodia_cchr_mamsonando.pdf និង សេចក្តីថ្លែងការណ៍ ម.ស.ម.ក "ម.ស.ម.ក រិះគន់ចំពោះសាលក្រមដែលរកឃើញថា លោក ម៉ម សូណង់ដូ មានទោស ថាជាការចំអកដល់ប្រព័ន្ធយុត្តិធម៌ និងជាការអាម៉ាស់សម្រាប់កេរ្តិ៍ឈ្មោះប្រទេសកម្ពុជា" ថ្ងៃទី១ ខែតុលា ឆ្នាំ២០១២ អាចអានបាន ៖http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=293&id=5

[47] កំណត់ត្រាសង្ខេប ម.ស.ម.ក "ករណីអ្នកការពារសិទ្ធិមនុស្ស លោក ម៉ម សូណង់ដូ" ខែសីហា ឆ្នាំ២០១២ អាចអានបាន ៖ http://www.ifex.org/cambodia/2012/08/03/cambodia_cchr_mamsonando.pdf ។

[48] ដូចខាងលើ។

[49] សេចក្តីថ្លែងការណ៍ ម.ស.ម.ក "ការចាប់ខ្លួនលោក ម៉ម សូណង់ដូ គឺជាការប៉ុនប៉ងដ៏គួរឲ្យខ្មាស់អៀនមួយដើម្បីកប់ចោលនូវជម្លោះក្នុងខេត្តក្រចេះ" ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ អាចអានបាន ៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=265&id=5 ។

"បទល្មើស" ក្នុងមាត្រា ៥៤៤ នៃក្រមព្រហ្មទណ្ឌ។ ការចោទប្រកាន់នេះអាចនឹងឲ្យលោក ចាន់ សុវ៉ែត ប្រឈមនឹងការជាប់ពន្ធនាគារចំនួន ៣ឆ្នាំ។[50] ការចោទប្រកាន់នេះកើតឡើងបន្ទាប់ពីមានសុន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ ដោយចោទប្រកាន់លើ "បុគ្គលិកផ្នែកសិទ្ធិមនុស្ស" ដែលមិនបង្ហាញអត្តសញ្ញាណ ថាបានជួយដល់ជនល្មើស។ មានការជឿថា បុគ្គលិកផ្នែកសិទ្ធិមនុស្សនោះសំដៅដល់លោក ចាន់ សុវ៉ែត ហើយដែលការចោទប្រកាន់នេះគឺផ្អែកលើសកម្មភាពការងារផ្នែកសិទ្ធិមនុស្សរបស់លោក ជាមួយនឹងសកម្មជនដីធ្លីពីខេត្តក្រចេះ។ សកម្មជនដីធ្លីរូបនេះត្រូវបានចោទប្រកាន់ថាមានការពាក់ព័ន្ធនឹងចលនាធ្វើអបគមន៍ ដែលមានបំណងបង្កើតរដ្ឋនៅក្នុងរដ្ឋ ក្នុងភូមិប្រម៉ា ខេត្តក្រចេះ ដែលជាកន្លែងដីសម្បទានសេដ្ឋកិច្ចចំនួន ១៥ ០០០ ហិកតា រៀបរាប់ខាងលើពាក់ព័ន្ធនឹងករណីរបស់ លោក ម៉ម សូណង់ដូ ដូចគ្នាដែរ។ កស្តុតាងនៃចលនាបង្កើតអបគមន៍នៅខេត្តក្រចេះនេះមិនទាន់មាននោះទេ។ ករណីលោក ចាន់ សុវ៉ែត គឺជាផ្នែកមួយនៃកំណើនការរំលោភបំពានដោយប្រើប្រព័ន្ធតុលាការ ដែលអាជ្ញាធរ និងអង្គការសិទ្ធិមនុស្ស និងបុគ្គលិកជំទែទៀតកំពុងតែជួបប្រទះជារៀងរាល់ថ្ងៃ។[51] ការកោះហៅនេះបង្ហាញពីការគំរាមកំហែងដើម្បីបង្អាក់ការរារាំង និងបំពានលើសកម្មជនសិទ្ធិមនុស្សក្នុងការអនុវត្តន៍សេរីភាពបញ្ចេញមតិស្របច្បាប់របស់ខ្លួននៅកម្ពុជា។

សេចក្តីសន្និដ្ឋាន

មិនគួរមានច្បាប់ផ្តន្ទាទោសមកលើ ការអនុវត្តន៍សេរីភាពបញ្ចេញមតិដោយស្របច្បាប់ របស់សមាជិកសភា អ្នកសារព័ត៌មាន ឬជាប្រជាពលរដ្ឋសាមញ្ញនោះទេ។ សេរីភាពបញ្ចេញមតិ ជាសសរស្តម្ភនៃលទ្ធិប្រជាធិបតេយ្យ ៖ សេរីភាពនេះជានាប្រសិទ្ធភាពនៃសំឡេងប្រជាពលរដ្ឋ និងជាការការពារសង្គមប្រឆាំងនឹងការរំលោភបំពានអំណាច និងអំពើពុករលួយក្នុងស្ថាប័នរដ្ឋ ដែលមានសារៈសំខាន់ចំពោះសង្គមដែលមានលទ្ធិប្រជាធិបតេយ្យពេញលេញ។ ការបង្កើតមជ្ឈដ្ឋាននៃការចាប់កំហុសខ្លួនឯង ធ្វើឲ្យអ្នកសារព័ត៌មាន និងសមាជិកសភាមិនហ៊ានបញ្ចេញគំនិតរបស់ខ្លួនព្រោះតែភ័យខ្លាចការប្តឹងផ្តល់ ឬមិនដូច្នោះទេត្រូវបានគេកំណត់ជាមុខសញ្ញា គឺនឹងមានតែកាត់បន្ថយនូវលទ្ធភាពនៃការទទួលបានព័ត៌មានក្នុងសង្គមថយចុះ។ ក្នុងឆ្នាំ២០១០ របាយការណ៍សង្ខេបដែលនិពន្ធរួមគ្នាដោយ ម.ស.ម.ក ដែលសរសេរថា "*សេរីភាពបញ្ចេញមតិរងការយាយីយ៉ាងធ្ងន់ធ្ងរជាបន្តបន្ទាប់[...] អត្ថិយឯកសិទ្ធិជាសមាជិកសភា របស់សមាជិកសភាគណបក្សប្រឆាំងត្រូវបានជីកហួតដើម្បីឲ្យមានការប្តឹងពី បទបរិហារកេរ្តិ៍ បទផ្តល់ព័ត៌មានមិនពិត និងបទញុះញង់ [...] ហើយការធ្វើឲ្យគំនិតមួយចំនួនក្លាយជា 'បទល្មើស' មានន័យថា ជាការបដិសេធសំឡេងប្រជាពលរដ្ឋ*" ។[52] រូបភាពរួមនេះនៅតែជាការបង្ហាញដ៏សង្ខេបស្ថានភាពបច្ចុប្បន្នពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិនៅកម្ពុជាបានយ៉ាងត្រឹមត្រូវ។ ប្រសិនបើមានរឿងអ្វីកើតឡើង ដែលជាលទ្ធផលនៃករណីដែលបានរៀបរាប់ខាងលើ ស្ថានភាពនឹងកាន់តែធ្ងន់ធ្ងរទៅជាមិនខាន។ បទបរិហារកេរ្តិ៍ និងបទល្មើសស្រដៀងគ្នាមួយចំនួនក្រោមក្នុងក្រមព្រហ្មទណ្ឌអន្តរកាល ត្រូវបានប្រើដើម្បីបំបាត់គំនិតជំទាស់របស់សមាជិកសភាគណបក្សប្រឆាំង ខណៈពេលដែលប្រជាពលរដ្ឋស៊ីវិលក៏ត្រូវបានផ្តន្ទាទោសផងដែរ ទាំងតាមរយៈក្រមព្រហ្មទណ្ឌអន្តរកាល និងក្រមព្រហ្មទណ្ឌ ចំពោះសកម្មភាពណាដែលមិនត្រូវបានចាត់ទុកក្នុងកម្រិតជាបទឧក្រិដ្ឋ និងដោយគ្មានសវនាការដ៏យុត្តិធម៌ ឬកស្តុតាងគ្រប់គ្រាន់ក្នុងការផ្តន្ទាទោសពួកគេនោះទេ។ ករណីទាំងនេះ បានបញ្ជាក់ថាប្រព័ន្ធតុលាការកម្ពុជាខ្វះខាតឯករាជ្យភាព

---

[50] អង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម "កម្ពុជា ៖ ការគំរាមកំហែងផ្នែកប្រព័ន្ធតុលាការ ក្នុងករណី លោក ចាន់ សុវ៉ែត" ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២ (KHM004/0812/OBS075) អាចអានបាន ៖ http://www.omct.org/human-rights-defenders/urgent-interventions/cambodia/2012/08/d21898/

[51] សេចក្តីប្រកាសព័ត៌មានបន្ទាន់ ម.ស.ម.ក "មន្ត្រីអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានសាលាដំបូងរាជធានីភ្នំពេញកោះហៅ" ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ អាចអានបាន៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=24&id=5 ។

[52] សកម្មភាពដើម្បីបរិស្ថាន និងសហគមន៍ និងផ្សេងៗ "កម្ពុជាត្រូវបានបំបិទមាត់ ៖ លទ្ធិប្រជាធិបតេយ្យកំពុងស្ថិតក្នុងគ្រោះថ្នាក់? របាយការណ៍ស្តីពីសេរីភាពបញ្ចេញមតិនៅកម្ពុជា" ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ ទំព័រទី១ អាចអានបាន ៖ http://www.cchrcambodia.org/admin/media/report/report/english/2010-09-14-%20Briefing%20Paper%20on%20Freedom%20of%20Expression%20in%20Cambodia-EN.pdf ។

និងសង្កត់ធ្ងន់មកលើឆន្ទៈនយោបាយរបស់ រដ្ឋាភិបាលក្នុងការប្រើច្បាប់ និងតុលាការដើម្បីគាបសង្កត់នូវរាល់ទម្រង់នៃគំនិតដែលមិនយល់ស្របនឹងរដ្ឋាភិបាល។

សារដ៏ច្បាស់មួយបានបញ្ជូនដល់អង្គការសង្គមស៊ីវិល និងសាធារណជនទូទៅថា នឹងគ្មានការអធ្យាស្រ័យដល់ គណបក្សប្រឆាំងនោះទេ ហើយរាល់ការរិះគន់នឹងត្រូវផ្តន្ទាទោស។ ដោយមិនគិតថាច្បាប់ណាចូលធរមាន គ្មានអ្នកប្រឆាំង ឬសកម្មជនណា ឬបុគ្គលដែលគាំទ្រពួកគេ នឹងមានគេចផុតពីការផ្តន្ទាទោសចំពោះការបញ្ចេញគំនិតដោយស្របច្បាប់នោះទេ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រហែលជាមិនអាចដកបទបរិហារកេរ្តិ៍ចេញពីបទឧក្រិដ្ឋ តែលោកពិតជាបានធ្វើតាមការព្រមានរបស់លោក កាលពីឆ្នាំ២០០៥ ចំពោះអ្នករិះគន់រូបលោក ដែលបានមានប្រសាសន៍ថា ៖ "*ចូរប្រយ័ត្នចំពោះភាសា "របបផ្តាច់ការ" ។ ចូរប្រុងប្រយ័ត្ន ថ្ងៃមួយនឹងមានការចាត់វិធានការស្របច្បាប់*"។[53]

ការណ៍នេះបង្ហាញឲ្យឃើញច្បាស់ថា និន្នាការនៃសេរីភាពបញ្ចេញមតិនៅកម្ពុជាឆ្ពោះទៅរក "ការគាបសង្កត់ដោយច្បាប់" មិនមែនជំណើរការ "នីតិរដ្ឋ" (គោលការណ៍ដែលគ្មានបុគ្គលណានៅពីលើច្បាប់) នោះទេ។ ខណៈពេលដែលក្នុងឆ្នាំ២០១២ ឃើញថាការប្រើប្រាស់អំពើហិង្សាជាអាវុធដ៏រស់រវើកក្នុងឃ្លាំងអាវុធរបស់រដ្ឋាភិបាល ដើម្បីបំបិទសំឡេងប្រជាពលរដ្ឋកម្ពុជា ក៏មានការកើនឡើងនៃគោលនយោបាយដ៏ទំនើបរបស់រដ្ឋាភិបាល បានយកប្រព័ន្ធតុលាការមកជំនួស ដើម្បីដើរតួជាអ្នកចាប់បង្ខំឲ្យអនុវត្តផងដែរ។ តាមរយៈការប្រើប្រាស់ភាពស្របច្បាប់បាំងមុខដែលច្បាប់ផ្តល់ឲ្យជាពិសេស ដើម្បីការពារការរិះគន់ និងការថ្កោលទោសពីសហគមន៍អន្តរជាតិ ក្នុងករណីដែលមានអំពើឃាតកម្ម ឬអំពើហិង្សា រដ្ឋាភិបាលកំពុងតែធ្វើការយ៉ាងស្ងប់ស្ងាត់ និងយ៉ាងខ្លាំងក្លា តាមរយៈប្រព័ន្ធតុលាការ និងនីតិបញ្ញត្ត ដើម្បីបង្កើត និងធ្វើឲ្យមានវប្បធម៌នៃភាពភ័យខ្លាច និងភាពស្ងាត់ស្ងៀមនៅកម្ពុជា។

ព័ត៌មានបន្ថែម សូមទំនាក់ទំនង កញ្ញា សន រ៉ាមណា មន្ត្រីសម្របសម្រួលគម្រោងសេរីភាពបញ្ចេញមតិ (ទូរសព្ទ ៖ +៨៥៥ (០) ១៧ ៦៥ ៥៥ ៩១ ឬ អ៊ីម៉ែល ៖ ramanasorn@cchrcambodia.org) **ឬ លោក រ៉ូប៊ឺត ហ្វីនច៍ ទីប្រឹក្សាជាន់ខ្ពស់ (ទូរសព្ទ ៖ +៨៥៥ (០) ៧៨ ៨០ ៩៩ ៦០ ឬ អ៊ីម៉ែល ៖** robert.finch@cchrcambodia.org) ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)
ខែតុលា ឆ្នាំ២០១១
ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

CC BY NC SA

បណ្ណាធិការ

ម.ស.ម.ក ត្រូវបានបង្កើតឡើងនៅក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកម្ពស់សិទ្ធិមនុស្ស និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅទូទាំងប្រទេសកម្ពុជា។

ម.ស.ម.ក គឺជាសមាជិករបស់ ដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អាយហ្វិក) ដែលជាបណ្តាញសកលដើម្បីការបញ្ចេញមតិដោយសេរី។

គេហទំព័រស្តីពីសិទ្ធិមនុស្សកម្ពុជា **www.sithi.org** ទទួលបានរង្វាន់ប្រចាំឆ្នាំ ២០១១ របស់មូលនិធិនៃការបង្កើតថ្មីសម្រាប់សង្គមព័ត៌មានវិទ្យា ក្នុងចំណាត់ថ្នាក់ សិទ្ធិ និងសេរីភាព។

[53] ដកស្រង់សម្តីដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន (កំណត់សម្គាល់បានបន្ថែម) ដកស្រង់ចេញពី "មិនមែនជារបបផ្តាច់ការនោះទេ" អា អេហ្វ ប៉េ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៩។